សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royal de Droit et des Economiques
Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# មោឃភាព និងការលុបចោល
# នៃអាពាហ៍ពិពាហ៍

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ៖ **ល .ឃាង មករា**
**ក .ហ៊ន ស្រីមុំម**

សាស្ត្រាចារ្យណែនាំ
**លោក ទេព សុខ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២០

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ឃាង មករា** និង **ហ៊ន ស្រីម៉ុម** ជានិស្សិតបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី២០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៦-២០២០។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ**

លោកអ្នកមានគុណទាំងពីរ ដែលបានផ្តល់កំណើតដល់យើងខ្ញុំ និងបានចិញ្ចឹមបីបាច់ថែរក្សាយ៉ាងយកចិត្តទុកដាក់ជាទីបំផុតប្រកបទៅដោយព្រហ្មវិហារធម៌ទាំងបួនផ្តល់ក្តីស្រលាញ់ និងភាពកក់ក្តៅដល់កូនគ្រប់ពេលវេលា។ ព្រមទាំងបានខិតខំពុះពារជំម្នះនូវគ្រប់ការលំបាកទាំងអស់ ដើម្បីកូនរហូតដល់ការបញ្ចប់ការសិក្សាថ្នាក់មហាវិទ្យាល័យនីតិសាស្ត្រ ជំនាញបរិញ្ញាបត្រនីតិសាស្ត្របានដោយជោគជ័យ។

អរគុណដល់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រកបទៅដោយគតិបណ្ឌិតបានផ្តល់សន្តិភាព ជូនជាតិមាតុភូមិបានយ៉ាងសុខសាន្តពិសេសបានផ្តល់គ្រឹះស្ថានយ៉ាងល្អប្រណិតក្នុងការសិក្សា និងបានបំពាក់នូវសម្ភារក្នុងការសិក្សាគ្រប់សម្បូរបែបដើម្បីធ្វើឲ្យការសិក្សាទទួលបាននូវលក្ខណៈងាយស្រួល។

សូមថ្លែងអំណរគុណចំពោះ ឯកឧត្តម **លុយ ចន្ធ្នា** សាកលវិទ្យាធិការ នៃសាលកវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតផ្តល់នឹងឪកាសដល់យើងខ្ញុំបានសិក្សានៅទីនេះ និងបានសរសេរសារណាដើម្បីបញ្ចប់ការសិក្សាផងដែរ។

លោកសាស្ត្រាចារ្យ **ទេព សុខ** ជាទីគោរពស្រលាញ់បំផុត របស់យើងខ្ញុំទាំងពីរដែលលោកតែងតែចំណាយពេលវេលាក្នុងការណែនាំជាច្រើន និងធ្វើការកែលម្អ ផ្តល់អនុសាសន៍សម្រាប់ យើងខ្ញុំក្នុងការសរសេរសារណារហូតទទួលបានជោគជ័យ។

អរគុណចំពោះមិត្តរួមថ្នាក់ទាំងអស់ដែលតែងតែជម្រុញ និងលើកទឹកចិត្តពួកខ្ញុំទាំងពីរនាក់ ក៏ដូចជាបានផ្តល់នូវគំនិតល្អៗក្នុងការតាក់តែងសារណានេះឡើងប្រកបទៅដោយបរិយាកាសរីករាយ និងស្និតស្នាលជាទីបំផុតក្នុងនាមមិត្តល្អ បងប្អូនល្អដែលតែងតែជួយគ្នាទៅវិញទៅមកគ្រប់គ្រាមានការលំបាក។

ជាចុងក្រោយ យើងខ្ញុំទាំងពីរសូមប្រសិទ្ធពរជ័យ សិរីសួស្តីចូលកើតមានដល់ លោកឪពុក អ្នកម្តាយ លោកសាស្ត្រាចារ្យ និងបងប្អូនមិត្តអ្នកអានទាំងអស់សមប្រកបជួបតែនូវពុទ្ធិពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាតឡើយ និងសូមទទួលបានជោគជ័យគ្រប់ភារៈកិច្ចទាំងអស់។

# **អារម្ភកថា**

មួប់សន្តិភាព ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា វាបានធ្វើឲ្យមានការរីកចម្រើនស្ទើរគ្រប់វិស័យទាំងអស់នាពេលបច្ចុប្បន្ន។ ពិសេសសម័យសន្តិភាពបានធ្វើឲ្យប្រជាពលរដ្ឋមានសិទ្ធិសេរីភាពពេញទី និងស្របទៅតាមបទបញ្ញត្តិរបស់ច្បាប់។ ដូច្នេះហើយបានជាប្រជាពលរដ្ឋមានសេរីភាពជាច្រើនយ៉ាងនៅក្នុងសកម្មភាពរស់នៅរបស់ខ្លួនជាពិសេស សិទ្ធិក្នុងការជ្រើសរើសគូស្រករដែលជាអនាគតរបស់បុរស នារី។

ដោយយល់ឃើញថា អាពាហ៍ពិពាហ៍ និង គ្រួសារជារឿងដែលសំខាន់បំផុតនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃពិសេសអាពាហ៍ពិពាហ៍ជាទំនាក់ទំនងមិត្តមួយរយឆ្នាំដែលត្រូវរស់នៅជាមួយគ្នាដោយមានការរួមសុខ រួមទុក្ខជាមួយគ្នារហូតតទៅដែលទាមទារឲ្យមនុស្សគ្រប់រូបគួរតែសិក្សា និងស្វែងយល់ពីអត្ថប្រយោជន៍អំពីវា ដោយសារមានការចេះដឹងនិងមានភ័ព្វសំណាងអាពាហ៍ពិពាហ៍របស់បុរស-នារីមួយចំនួនក៏បានសមប្រកបមានសុភមង្គល ចំណែកអាពាហ៍ពិពាហ៍ខ្លះទៀតក៏មានវិការៈ ដែលជាហេតុនាំមានការសោកស្តាយក្នុងការដោយមានមូលហេតុជាច្រើននៅជាប់ពាក់ព័ន្ធពីក្រោយ។

ហេតុនេះហើយ បានជាយើងខ្ញុំទាំងពីរនាក់បានធ្វើការសម្រេចចិត្តក្នុងជ្រើសរើសនូវ ប្រធានបទស្តីអំពី **មោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍** មកចងក្រងឡើង។ ដើម្បីជាជំនួយស្មារតីដល់ប្រជាពលរដ្ឋក្នុង ការយល់ដឹងឱ្យបានកាន់តែច្បាស់អំពីហេតុផលទាំងឡាយដែលនាំឲ្យអាពាហ៍ពិពាហ៍នោះ ត្រូវបានធ្វើការមោឃ និងឈានដល់ការលុបចោល ជាហេតុទាមទារឲ្យអ្នកទាំងអស់នោះបានយល់ពីដំណើរប្រព្រឹត្តទៅនៃការរៀបអាពាហ៍ពិពាហ៍ ពិសេសមូលហេតុអ្វីខ្លះនៅពីក្រោយនៃការមោឃភាព និងការលុបចោលនេះ។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា កម្រងឯកសារស្តីអំពីប្រធានបទខាងលើនេះ វានឹងផ្តល់ជាសារៈសំខាន់ដល់និស្សិតជំនាន់ក្រោយៗ និងជូនជាស្មារតីទៅកាន់ប្រជាពលរដ្ឋទាំងអស់បានសិក្សាស្វែងយល់បន្ថែមអំពីប្រព័ន្ធគតិយុត្តដែលជាប់ការពាក់ព័ន្ធទៅនឹងហេតុដែលបាននាំឲ្យមានការមោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍។ អាស្រ័យហេតុនេះហើយ ខ្ញុំទាំងពីររូបសូមមេត្តាខន្តីអភ័យទោសជាមុនចំពោះកំហុសឆ្គងណាមួយដែលកើតមានដោយអចេតនានូវអក្ខរាវិរុទ្ធត្រង់ណាដែលមិនសមរម្យត្រង់ប្រការណាមួយដោយក្តីមេត្តាអនុគ្រោះ។

ជាចុងក្រោយ យើងខ្ញុំទាំងពីររូបសូមធ្វើការខន្តីអភ័យទោសទុកជាមុន ពីសំណាក់មិត្តអ្នកអានទាំងអស់ចំពោះកំហុសឆ្គងដែលបានកើតមានឡើងដោយការភ្លេចភ្លាំង ឬដោយអចេតនាត្រង់ណានោះមួយដែលបានកើតមានឡើង។ ជាទីបញ្ចប់យើងខ្ញុំទាំងពីររូប សូមស្វាគមន៍យ៉ាងកក់ក្តៅនូវរាល់ការរិះគន់ក្នុងវត្ថុបំណងធ្វើការស្ថាបនាពីសំណាក់មិត្តអ្នកអានទាំងអស់ដោយក្តីសោមនស្សរីករាយជាទីបំផុត។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ............................................................ ១

## ជំពូកទី១

## នីតិវិធីនៃការបង្កើតអាពាហ៍ពិពាហ៍

**១.១ លក្ខខណ្ឌនៃការបង្កើតអាពាហ៍ពិពាហ៍** ........................................ ៣

**១.១.១ និយមន័យ** ........................................ ៣

**១.១.២ របបគតិយុត្តក្នុងការបង្កើតអាពាហ៍ពិពាហ៍** ........................................ ៣

១.១.២.១ លក្ខខណ្ឌគ្រឹះក្នុងការបង្កើតអាពាហ៍ពិពាហ៍ ........................................ ៤

ក. លក្ខខណ្ឌអាយុ ........................................ ៤

ខ. លក្ខខណ្ឌទាក់ទងទៅនឹងសមត្ថភាព ........................................ ៥

គ.លក្ខខណ្ឌទាក់ទងនឹងការព្រមព្រៀង ........................................ ៦

ឃ. លក្ខខណ្ឌឯកពទ្ធភាព ........................................ ៧

ង. លក្ខខណ្ឌទាក់ទងទៅនឹងទំនាក់ទំនងញាតិរវាងគូរភាគី ........................................ ៧

១.១.២.២ លក្ខខណ្ឌទម្រង់នៃការបង្កើតអាពាហ៍ពិពាហ៍ ........................................ ៨

ក.ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ........................................ ៩

ខ.ការប្រកាសផ្សាយជាសាធារណៈ ........................................ ៩

គ. ការចុះបញ្ជីអាពាហ៍ពិពាហ៍ ........................................ ១០

**១.២ ទម្រង់នៃការរៀបអាពាហ៍ពិពាហ៍** ........................................ ១១

**១.២.១ នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ** ........................................ ១១

**១.២.២ នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ ឬរវាងពលរដ្ឋខ្មែរ និង ជនបរទេស នៅបរទេស**. ១២

**១.២.៣ នីតិវិធីក្នុងការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនៅក្នុងប្រទេសកម្ពុជា** .......... ១៣

## ជំពូកទី២

## មោឃភាពនៃអាពាហ៍ពិពាហ៍

**២.១ សញ្ញាណគតិយុត្តនៃមោឃភាពកិច្ចសន្យា** ........................................ ១៦

**២.១.១ និយមន័យនៃមោឃភាព** ........................................ ១៦

**២.១.២ មូលហេតុនៃមោឃភាពកិច្ចសន្យា ........ ១៦**

២.១.២.១ ការបង្ហាញឆន្ទៈមិនពិត ........ ១៧

២.១.២.២ អត្ថន័យនៃកិច្ចសន្យាផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ ........ ១៨

២.១.២.៣ អត្ថន័យនៃកិច្ចសន្យាផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ ........ ១៩

២.១.២.៤ កិច្ចសន្យាផ្ទុយនឹងទម្រង់ដែលបានទាមទារដោយច្បាប់ ........ ២០

២.១.២.៥ ការតំណាងដោយគ្មានសិទ្ធិ ........ ២១

**២.២ បញ្ញត្តិជាមូលដ្ឋាននៃការមោឃភាពនៃអាពាហ៍ពិពាហ៍ ........ ២១**

**២.២.១ មូលហេតុដោយគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ ........ ២៣**

**២.២.៣ មូលហេតុមិនបានគោរពតាមនីតិវិធី ........ ២៤**

**២.៣ នីតិវិធីនៃការមោឃភាពអាពាហ៍ពិពាហ៍ ........ ២៤**

**២.៣.១ បុគ្គលដែលមានសិទ្ធិក្នុងការធ្វើមោឃភាព ........ ២៤**

**២.៣.២ សមត្ថកិច្ចដោះស្រាយលើបណ្តឹងមោឃភាពអាពាហ៍ពិពាហ៍ ........ ២៥**

**២.៣.៣ អានុភាពនៃការមោឃភាពអាពាហ៍ពិពាហ៍ ........ ២៥**

## ជំពូកទី៣

## ការលុបចោលនៃអាពាហ៍ពិពាហ៍

**៣.១ មូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍ ........ ២៧**

**៣.១.១ មូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ ........ ២៨**

៣.១.១.១ មិនគ្រប់អាយុរៀបអាពាហ៍ពិពាហ៍ ........ ២៨

៣.១.១.២ អាពាហ៍ពិពាហ៍រវាងញាតិលោហិត ........ ២៨

៣.១.១.៣ អាពាហ៍ពិពាហ៍ចំពោះញាតិពន្ធ ........ ២៩

៣.១.១.៤ អាពាហ៍ពិពាហ៍អំឡុងពេលហាមឃាត់ ........ ២៩

៣.១.១.៥ ទ្វេពទ្ធភាព ........ ២៩

៣.១.១.៦ អាពាហ៍ពិពាហ៍ដោយការឆបោក ឬដោយការគំរាម ........ ៣០

**៣.១.២ មូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ........ ៣០**

៣.១.២.១ អាពាហ៍ពិពាហ៍ដោយគ្មានឆន្ទៈ ឬ ដោយការបង្ខិតបង្ខំ ........ ៣១

៣.១.២.២ អាពាហ៍ពិពាហ៍ដោយភ្នាក់ងាររើសគូស្រករ ........ ៣១

៣.១.២.៣ អាពាហ៍ពិពាហ៍ដោយការឆបោក ........................................................ ៣១

**៣.២ នីតិវិធីនៃការលុបចោល** ........................................................ ៣២

**៣.២.១ អាជ្ញាយុកាលនៃការប្តឹងលុបចោល** ........................................................ ៣២

៣.២.១.១ អាជ្ញាយុកាលដែលកំណត់ដោយច្បាប់ ........................................................ ៣២

៣.២.១.២ អាជ្ញាយុកាលដែលកើតឡើងដោយការបន្ទាញឆន្ទៈ ........................................................ ៣៣

**៣.២.២ ភាគីដែលមានសិទ្ធិប្តឹងលុបចោលអាពាហ៍ពិពាហ៍** ........................................................ ៣៣

៣.២.២.១ ភាគីជាសហព័ទ្ធផ្ទាល់ ........................................................ ៣៣

៣.២.២.២ ញាតិរបស់ភាគី ........................................................ ៣៤

៣.២.២.៣ តំណាងអយ្យការ ........................................................ ៣៤

**៣.៣ អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍** ........................................................ ៣៥

**៣.៣.២ អានុភាពចំពោះបុគ្គល** ........................................................ ៣៥

៣.៣.២.១ ចំពោះសាមីខ្លួនទាំងសងខាង ........................................................ ៣៥

៣.៣.២.២ ចំពោះបុត្តភាព ........................................................ ៣៦

**៣.៣.៣ អានុភាពចំពោះទ្រព្យ** ........................................................ ៣៧

៣.៣.៣.១ ចំពោះទ្រព្យសកម្ម ........................................................ ៣៧

ក. ប្រព័ន្ធទ្រព្យសម្បត្តិតាមវិធានកិច្ចសន្យា ........................................................ ៣៧

ខ.ប្រពន្ធ័ទ្រព្យសម្បត្តិកំណត់តាមច្បាប់ ........................................................ ៣៧

៣.៣.៣.២ ចំពោះអកម្មទ្រព្យ ........................................................ ៣៩

ក. អកម្មទ្រព្យដោយឡែក ........................................................ ៣៩

ខ. អកម្មទ្រព្យរួម ........................................................ ៣៩

**សេចក្តីសន្និដ្ឋាន** ........................................................ ៤០

**អនុសាសន៍** ........................................................ ៤២

**ឯកសារយោង**

**ឧបសម្ពន្ធ**

# សេចក្តីផ្តើម

ដោយប្រកាន់ជំហរផ្អែកទៅលើលក្ខខណ្ឌធម្មជាតិ នៃមនុស្សជាតិលើពិភពលោកនេះ គ្រប់រូបវន្តបុគ្គលដែលឈានដល់វ័យនីតិភាពទាំងអស់ មិនថាពួកគេរស់នៅក្នុងស្ថានភាពក្រលំបាក ឬឋិតនៅក្នុងស្ថានភាពល្អប្រសើរយ៉ាងណានោះទេ ឲ្យតែដល់វ័យនីតិភាពសេចក្តីស្រលាញ់របស់ពួកគេបានរមែងកើតមានឡើង ចំពោះអន្តរកម្មទៅវិញទៅមក ហើយក្តីស្រលាញ់នេះវាកើតមានដោយមិនធ្វើការប្រកាន់អំពីនិន្នាការនយោបាយ វណ្ណៈទំនៀមទម្លាប់ ប្រពៃណី ពូជសាសន៍ សាសនា ថាដូចគ្នា ឬខុសគ្នាឡើយ។ ហេតុនេះហើយក្តីស្រលាញ់មួយនេះវាធ្វើឲ្យពួកគេឈានទៅដល់ការរៀបអាពាហ៍ពិពាហ៍មួយទៅតាមបវេណី និងប្រព្រឹត្តទៅដោយស្របទៅតាមនីតិវិធីច្បាប់ដែលបានកំណត់។ អាស្រ័យហេតុនេះហើយ ទើបយើងឃើញថាគឺមានអាពាហ៍ពិពាហហ៍ជាច្រើនដែលសព្វថ្ងៃនេះនៅក្នុងប្រទេសកម្ពុជាយើងកំពុងតែបានដំណើរការយ៉ាងប្រក្រតី ដោយអាពាហ៍ពិពាហ៍ខ្លះមានការព្រមព្រៀងគ្នាទៅតាមផ្លូវច្បាប់ ហើយមានចិត្តស្មោះស្ម័គ្ររវាងគ្នា នឹងគ្នាដោយគ្មានវិការៈណាទេនោះ ព្រមទាំងមានការទទួលស្គាល់ អំពីសំណាក់អាជ្ញាធរមានសមត្ថកិច្ចវាជារឿងដែលល្អបំផុតសម្រាប់ជីវិតពួកគេ។ យ៉ាងណាមិញទោះបីជាមានអាពាហ៍ពិពាហ៍មួយចំនួន វាត្រូវបានអនុលោមទៅតាមច្បាប់ស្របតាម ឆន្ទះរបស់គូភាគីក៏ពិតមែនក៏ប៉ុន្តែ នៅក្នុងទិដ្ឋភាពជាក់ស្តែងសព្វថ្ងៃនេះ យើងមើលថាមានអាណាព្យាបាលមួយចំនួនដោយប្រកាន់ថាខ្លួនជាចាស់ទុំ ហើយត្រូវបានបង្ខិតបង្ខំកូនៗរបស់ពួកគាត់ឲ្យរៀបអាពាហ៍ពិពាហ៍ទាំងបង្ខំចិត្ត ទាំងមិនមានការយល់ព្រមអំពីសំណាក់សាមីខ្លួនដែលជាភាគីផ្ទាល់ឡើយ។ ចំណែកឯអាពាហ៍ពិពាហ៍ខ្លះទៀតត្រូវបានធ្វើឡើងក្នុងរូបភាពគម្រាមគំហែង ខ្លះទៀតធ្វើឡើងដោយរូបភាពគំនិតអាក្រក់ដែលមានលក្ខណៈក្នុងការឆបោកចង់បាននូវ អ្វីមួយអំពីសំណាក់ភាគីណាមួយ ចំណែកឯនៅជនបទវិញអាពាហ៍ពិពាហ៍មួយចំនួនតូចហាក់បីជាមិនមានអាយុគ្រប់គ្រាន់ទេ និងមានចំណុចអវិជ្ជមានជាច្រើនទៀត នៅក្នុងដំណើរការប្រព្រឹត្តទៅនៃការរៀបអាពាហ៍ពិពាហ៍បច្ចុប្បន្ននេះ ចំណុចអវិជ្ជមានទាំងនេះហើយបានជាទាមទារឲ្យប្រជាពលរដ្ឋគ្រប់រូបត្រូវមានសិក្សាស្វែងយល់អំពីវិការៈដែលតែងតែកើតមានឡើងនៅពេលរៀបអាពាហ៍ពិពាហ៍។

អាស្រ័យហេតុនេះហើយ យើងខ្ញុំទាំងពីររូបបានសម្រេចលើកយកប្រធានបទទាក់ទង់នឹង មោឃភាពនិងការលុបចោលអាពាហ៍ពិពាហ៍ មកធ្វើការបកស្រាយ។ ដោយប្រធានបទនេះ វាមានលក្ខណៈពិសេសក្នុងការចង្អុលបង្ហាញ អំពីភាពខុសឆ្គងទាំងឡាយដែលតែងពើងប្រទះជួបក្នុងការអនុវត្តជាក់ស្តែងនាពេលបច្ចុប្បន្នម្យ៉ាងវិញគឺដើម្បីចូលរួមធ្វើការកែលម្អការអនុវត្តច្បាប់ប្រកបទៅដោយប្រសិទ្ធភាព និងចូលរួមក្នុងការចែករំលែកនូវចំណេះដឹងជូនដល់ប្រជាពលរដ្ឋ។

ដូច្នេះហើយទើបមានចំណោទបញ្ហាមួយចំនួនបានកើតមានឡើង ក្នុងរង្វង់ជុំវិញនៃប្រធានបទខាងលើបានលើកឡើងថា តើអ្វីទៅជា អាពាហ៍ពិពាហ៍ នៅក្នុងប្រព័ន្ធច្បាប់កម្ពុជាសព្វថ្ងៃ? ហើយអាពាហ៍ពិពាហ៍ត្រូវធ្វើ

បែបណាទើបមានអានុភាពគតិយុត្ត? តើមានមូលហេតុអ្វីខ្លះបានជានាំឲ្យអាពាហ៍ពិពាហ៍នោះត្រូវបានមោឃ និងធ្វើការលុបចោល? ក្រោយពីមោឃភាព និងលុបចោលអាពាហ៍ពិពាហ៍ តើវាមានអានុភាពយ៉ាងដូចម្ដេចខ្លះ?

ដូច្នេះដើម្បីធ្វើការឆ្លើយតបទៅ នឹងបញ្ហាគតិយុត្តដែលបានលើកឡើងខាងលើនេះ ក្នុងនាមយើងខ្ញុំជាអ្នកអធិប្បាយនូវប្រធានបទខាងលើនេះ សូមធ្វើការញែកចេញជាបីជំពូកៈ

**ជំពូកទី១ នីតិវិធីនៃបង្កើតអាពាហ៍ពិពាហ៍**

១.១ លក្ខខណ្ឌនៃការបង្កើតអាពាហ៍ពិពាហ៍

១.២ ទម្រង់នៃការរៀបអាពាហ៍ពាហ៍

**ជំពូកទី២ មោឃភាពនៃអាពាហ៍ពិពាហ៍**

២.១ សញ្ញាណគតិយុត្តនៃមោឃភាពកិច្ចសន្យា

២.២ បញ្ញត្តិជាមូលដ្ឋាននៃការមោឃភាព នៃអាពាហ៍ពិពាហ៍

២.៣ នីតិវិធីនៃការមោឃភាពអាពាហ៍ពិពាហ៍

**ជំពូកទី៣ ការលុបចោលនៃអាពាហ៍ពិពាហ៍**

៣.១ មូលហេតុនៃការលុបចោល

៣.២ នីតិវិធីនៃការលុបចោល

៣.៣ អានុភាពនៃការលុបចោល

# ជំពូកទី១
# នីតិវិធីនៃការបង្កើតអាពាហ៍ពិពាហ៍

## ១.១ លក្ខខណ្ឌនៃការបង្កើតអាពាហ៍ពិពាហ៍

ជាគោលការណ៍ដោយផ្អែកតាមលក្ខខណ្ឌធម្មជាតិបុរស និងនារី ដែលមានវ័យនីតិភាពដែលពាក្យចាស់តែងតែលើកឡើងថាពេញកំលោះ ពេញក្រមុំនោះ វាជាវ័យមួយពោលពេញទៅដោយសេចក្ដីស្នេហា ជាការវិឌ្ឍន៍ទៅរកការបង្កើតអាពាហ៍ពិពាហ៍ របស់ពួកគេទៅតាមទំនៀមទម្លាប់ពីបុរាណកាលមក។ ម្យ៉ាងវិញទៀតនោះ បើផ្អែកទៅលើខ្លឹមសារ នៃច្បាប់ក៏មិនធ្វើការអនុញ្ញាតឲ្យមានអាពាហ៍ពិពាហ៍មួយ ចេះតែប្រព្រឹត្តទៅតាមតែទំនើងចិត្តនោះដែរ។ អាស្រ័យហេតុនេះហើយបានជាអាពាហ៍ពិពាហ៍ ត្រូវតែបង្កើតឡើងទៅតាមលក្ខខណ្ឌដូចដែលច្បាប់បានកំណត់ ពីព្រោះអាពាហ៍ពិពាហ៍វាជាមូលដ្ឋានមួយក្នុងការបង្កើតបានជាគ្រួសារមួយ ដែលមានការរស់នៅប្រកបទៅដោយសុភមង្គល ដោយឈរលើគោលការណ៍នៃការស្ម័គ្រចិត្ត និងសមភាពហើយត្រូវបានច្បាប់ធ្វើការទទួលស្គាល់។

### ១.១.១ និយមន័យ

គេបានឲ្យនិយមន័យថា អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារិកមួយដែលបានធ្វើឡើងដោយបុរសម្នាក់ នឹងជាមួយស្ត្រីម្នាក់ដែលបានប្ដេជ្ញាថា នឹងរួមសមគ្គសង្វាជាមួយគ្នាគោរពតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញតាមទំនើងចិត្តរបស់ខ្លួនបានឡើយ។[1]

ក្នុងន័យទូទៅវិញ គេបានឲ្យនិយមន័យទៅលើអាពាហ៍ពិពាហ៍ថា អាពាហ៍ពិពាហ៍គឺជាមូលដ្ឋានរបស់គ្រួសារដែលមានទំនាក់ទំនងថ្លៃថ្លារវាងបុរស និងនារី សម្រាប់ជាគូរស្វាមីភរិយាបង្កើតបានជាកោសិកាសង្គមអនុវត្តភារៈសំខាន់របស់សង្គម។

### ១.១.២ របបគតិយុត្តក្នុងការបង្កើតអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍ជារឿងដែលសំខាន់ និងចាំបាច់បំផុតសម្រាប់ជោគវាសនារបស់ បុរស និង នារី ដូច្នេះអាពាហ៍ពិពាហ៍មួយ ត្រូវតែគោរពនូវគោលការណ៍តាមបញ្ញត្តិច្បាប់ជាធរមាន។ ជាក់ស្តែងគឺនៅក្នុងប្រទេសកម្ពុជាយើង ដើម្បីបង្កើតអាពាហ៍ពិពាហ៍មួយមានអានុភាពគតិយុត្តសមស្របទៅតាមច្បាប់បាននោះ លុះត្រាតែមានការគោរពនូវលក្ខខណ្ឌធំៗចំនួន**២** គឺលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់។ ពីព្រោះលក្ខខណ្ឌទាំងពីរនេះវាជាការធានាបានថាការបង្កើតនូវអាពាហ៍ពិពាហ៍មួយដែលមានភាពសមស្រប នាំឲ្យមានអានុភាពគតិយុត្ត ដែលដំបូងនេះយើងនឹងលើកយកលក្ខខណ្ឌគ្រឹះមកធ្វើការសិក្សាជាមុនសិន។

---

[1] មាត្រា ៣ នៃច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ២០០៦

### ១.១.២.១ លក្ខខណ្ឌគ្រឹះក្នុងការបង្កើតអាពាហ៍ពិពាហ៍

#### ក. លក្ខខណ្ឌអាយុ

បុរស និង នារី ដែលជាភាគីនៃចំណងអាពាហ៍ពិពាហ៍ នៅក្នុងក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាបានធ្វើការបញ្ញត្តិថាអាយុដែលគ្រប់នឹងលក្ខណៈ ក្នុងការរៀបអាពាហ៍ពិពាហ៍សំដៅដល់វ័យ នីតិភាព។ ប៉ុន្តែក្នុងករណីដែលភាគីម្ខាងបានដល់វ័យនីតិភាព ហើយភាគីម្ខាងទៀតនៃ ចំណងអាពាហ៍ពិពាហ៍ជាអនីតិជនដែលមានអាយុមិនតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ ក៏គេអាចរៀបអាពាហ៍ពិពាហ៍បានដែរ ដោយមានការទទួលយល់ព្រមពីអ្នកមានអំណាចមេបា ឬអាណាព្យាបាលសម្រាប់អនីតិជនរបស់អនីតិជននោះ។[2] យ៉ាងណាចំពោះច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ បានធ្វើការបង្ហាញអំពីលក្ខខណ្ឌអាយុកាន់ឲ្យតែច្បាស់លាស់ថែមទៀត ដោយបានចង្អុលប្រាប់ថា បុរសដែលមានអាយុចាប់ពី ២០ ឆ្នាំឡើងទៅ ទើបមានសិទ្ធិគ្រប់គ្រាន់ក្នុងការរៀបអាពាហ៍ពិពាហ៍បាន ចំណែកឯខាងនារីវិញ ត្រូវបានបញ្ញត្តិចាប់ពីអាយុ ១៨ ឆ្នាំឡើង។ យ៉ាងណាមិញក៏មានអញ្ញត្តិកម្មនៃច្បាប់នេះក៏បានលើកឡើងករណីពិសេសផងដែរ ដោយបញ្ញត្តិថាបុរសដែលមានអាយុមិនទាន់ដល់ ២០ ឆ្នាំនិងនារីដែលមានអាយុមិនទាន់ដល់ ១៨ ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍ស្របច្បាប់បាន ប្រសិនណាជានារីនោះមានផ្ទៃពោះ ហើយមានការអនុញ្ញាតពីឪពុកម្តាយ ឬអ្នកអាណាព្យាបាល។[3] សូមបញ្ជាក់ថា ភាគីណាម្នាក់នឹងបានដល់នីតិភាព នៅពេលដែលគាត់បានដល់អាយុ ១៨ ឆ្នាំ ឬក៏ទទួលបាននូវអត្តាធីនភាព។ ទន្ទឹមនឹងនេះផងដែរ អនីតិជននឹងទទួយបាននូវអត្តាធីនភាព នៅក្នុងករណីពីរយ៉ាងរួមមាន៖

- តាមរយៈដីកាសម្រេចរបស់តុលាការ ដែលបានសម្រេចផ្តល់អត្តាធីនភាពដោយផ្អែកតាមពាក្យសុំរបស់អនីតិជនដែលបានដល់អាយុ ១៦ ឆ្នាំ។
- តាមរយៈការរៀបអាពាហ៍ពិពាហ៍របស់អនីតិជននោះ។

ដើម្បីឲ្យកាន់តែមានភាពសុក្រឹត និងច្បាស់លាស់បន្ថែមទៀតនោះ យើងខ្ញុំសូមធ្វើការលើកឡើងនូវ ឧទាហរណ៍មួយចំនួនមកបកស្រាយដើម្បីជាសំអាងក្នុងការលើកឡើងខាងលើនេះ។

**ឧទាហរណ៍ ៖** កញ្ញា ក នាងមានអាយុទើបតែ ១៦ ឆ្នាំតែប៉ុណ្ណោះ ប៉ុន្តែនាងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទ្រទ្រង់នូវជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួន ដោយមិនចាំបាច់ពឹងផ្អែកពីសំណាក់ឪពុកម្តាយរបស់នាងនោះឡើយ។ ក្នុងករណីបែបនេះ ប្រសិនណាជាកញ្ញារូបនេះ ចង់បាននូវអត្តាធីនភាព កញ្ញាត្រូវតែដាក់ពាក្យសុំទៅកាន់តុលាការនៃលំនៅឋានរបស់ខ្លួន ដើម្បីធ្វើការស្នើសុំអត្តាធីនភាពនេះ (យោងតាមច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង)។ ដូច្នេះក្រោយពីនាងទទួលបាន នូវអត្តាធីនភាពតាមដីកាសម្រេចរបស់តុលាការ

[2] មាត្រា ៩៤៨ នៃក្រមរដ្ឋប្បវេណី ២០០៧

[3] មាត្រា ៥ នៃច្បាប់ស្តីពីឯកពន្ធភាព និងគ្រួសារ ១៩៨៩

ហើយនោះ ប្រសិនជាកញ្ញា ក នោះចង់រៀបអាពាហ៍ពិពាហ៍ជាមួយបុរសណាម្នាក់ដែលនាងពេញចិត្តនោះ គឺនាងមិនចាំបាច់ស្នើសុំការអនុញ្ញាតយល់ព្រមពីឪពុកម្ដាយរបស់នាងទេ។

**ឧទាហរណ៍ ៖** កញ្ញា ខ នាងមានអាយុទើបតែ ១៦ ឆ្នាំប៉ុណ្ណោះ។ កញ្ញាបានរៀបអាពាហ៍ពិពាហ៍ជាមួយលោក ខ ដោយមានការយល់ព្រមពីសំណាក់ឪពុកម្ដាយរបស់កញ្ញា។ ក្រោយពីចុះសំបុត្រអាពាហ៍ពិពាហ៍រួច កញ្ញា ខ នឹងទទួលបាននូវអត្តាធីនភាពដោយស្វ័យប្រវត្តិ ដោយមិនចាំបាច់ស្នើសុំពីតុលាការឡើយ។

**ខ. លក្ខខណ្ឌទាក់ទងទៅនឹងសមត្ថភាព**

ជាគោលការណ៍ អាពាហ៍ពិពាហ៍ត្រូវតែមានសមត្ថភាពគ្រប់គ្រាន់ នឹងមានឆន្ទះក្នុងការរៀបអាពាហ៍ពិពាហ៍។ ប៉ុន្តែច្បាប់នៅតែបើកចំហរឲ្យមានអញ្ញត្តិកម្មសម្រាប់បុគ្គលមួយចំនួនក្នុងនោះរួមាន ជនដែលនៅក្រោមអាណាព្យាបាលទូទៅ ជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភជាដើម។

ចំពោះជនដែលស្ថិត នៅក្នុងស្ថានភាពដែលមានកម្រិតខ្វះសមត្ថភាពក្នុងការយល់ដឹង និងការវិនិច្ឆ័យអំពីបញ្ហាច្បាប់មានកម្រិតបែបដោយសារស្ថានភាពវិបត្តិផ្នែកស្មារតី ក៏ពួកគាត់ទាំងនោះអាចរៀបអាពាហ៍ពិពាហ៍បានដែរ នៅក្នុងករណីដែលជនទាំងនេះមានសមត្ថភាពបង្ហាញឆន្ទៈ ក្នុងកម្រិតអតិបរមា ដែលចាំបាច់ដើម្បីអាចរៀបអាពាហ៍ពិពាហ៍។ ក្នុងករណីនេះពួកគាត់មិនធ្វើការចាំបាច់សុំការអនុញ្ញាត ឬមានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅឡើយ។[4]

**ឧទាហរណ៍៖** កញ្ញា ក មានអាយុ ២១ ឆ្នាំ និងលោក ខ គាត់មានអាយុ ២៥ ឆ្នាំ មានគម្រោងរៀបអាពាហ៍ពិពាហ៍នឹងគ្នាក្នុងពេលឆាប់ៗខាងមុខ។ ជាអកុសលមិនទាន់បានរៀបអាពាហ៍ពិពាហ៍ផង កញ្ញា ក មានឧបទ្ទវហេតុជួបគ្រោះថ្នាក់ចរាចរណ៍នៅតាមដងផ្លូវ បានបង្កឲ្យកញ្ញា ក បាត់បង់ស្មារតីមិនដឹងខុសត្រូវមួយរយៈពេល។ ហេតុដូចនេះ កញ្ញា ក ត្រូវបានដាក់ឲ្យស្ថិតនៅក្រោម អាណាព្យាបាលទូទៅតាមដីកាសម្រេចរបស់តុលាការ។ ក្រោយមក ដោយមានការយកចិត្តទុកដាក់ពីសំណាក់អ្នកអាណាព្យាបាលទូទៅធ្វើឲ្យកញ្ញា ក មានសុខភាពល្អប្រសើរឡើងវិញ ក៏ប៉ុន្តែមិនទាន់បានជាសះស្បើយទាំងស្រុងនៅឡើយទេ។ ក្នុងករណីនេះ កញ្ញា ក អាចធ្វើការបង្ហាញឆន្ទៈក្នុង ការរៀបអាពាហ៍ពិពាហ៍បាននៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នោះអ្នកទាំងពីរនឹង អាចរៀបអាពាហ៍ពិពាហ៍បាន ដោយមិនចាំបាច់ឆ្លងកាត់ការយល់ព្រមពីអ្នកអាណាព្យាបាលបានទេ។

ចំពោះជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភវិញ បើទោះបីជាបុគ្គលដែលស្ថិតនៅក្នុងស្ថានភាពបែបនេះគេមានការយល់ដឹងមានកម្រិតតិចតួចក៏ដោយ ច្បាប់នៅតែអនុញ្ញាតឲ្យគាត់រៀបអាពាហ៍ពិពាហ៍បានដោយមិនចាំបាច់មានការយល់ព្រមពីសំណាក់ហិតូបត្ថម្ភនោះឡើយ។[5]

---

4 មាត្រា ៩៥៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

5 មាត្រា ៣០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**ឧទាហរណ៍៖** លោក ក គាត់មានវ័យ ២៩ ឆ្នាំ។ នៅថ្ងៃមួយគាត់បានរបូតជើងធ្លាក់ពីជណ្តើរដែលមានកម្ពស់៤ ម៉ែត្របានប៉ះពាល់ដល់ខួរក្បាល ធ្វើឲ្យគាត់មិនសូវដឹងខុសត្រូវដូចគ្រាមុនឡើយ។ ប៉ុន្តែគ្រូពេទ្យជំនាញបានប្រាប់ថាគាត់មិនមែនមិនដឹងខុសត្រូវទាំងស្រុងនោះទេ គ្រាន់តែអាចយល់ដឹងតិចតួចៗ ។ ដូចនេះតុលាការនឹងចេញដីកាសម្រេច ឲ្យលោក ក ស្ថិតនៅក្រោមហិតូបត្ថម្ភ។ ទោះបីជាយ៉ាងនេះក្តី លោក ក នៅតែអាចរៀបអាពាហ៍ពិពាហ៍បានដដែរ ដោយមិនចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈនោះឡើយ។

**គ.លក្ខខណ្ឌទាក់ទងនឹងការព្រមព្រៀង**

ជាគោលការណ៍អាពាហ៍ពិពាហ៍ គឺជាការព្រមព្រៀងដែលធ្វើឡើងដោយការស្ម័គ្រចិត្តទាំងបុរស-ទាំងនារីដោយឯកឯង។ សំដៅដល់សេរីភាពក្នុងការសម្រេចចិត្ត ដោយសេរីភាពពេញលេញពោលគឺ មិនត្រូវបានបង្ខិតបង្ខំឬគំរាមគំហែង ឬមានការឆបោក ឬមានការភ័ន្តច្រឡំនោះឡើយ។[6] បានសេចក្តីថាភាគីម្ខាងមិនអាចបង្ខំឲ្យភាគីម្ខាងទៀត ឲ្យរៀបអាពាហ៍ពិពាហ៍ដោយផ្ទុយនឹងឆន្ទៈរបស់គេឡើយ។ ជាគោលការណ៍ស្ម័គ្រចិត្តនៅក្នុងការរៀបអាពាហ៍ពិពាហ៍នេះ ត្រូវបានចារឹកទុកក្នុងរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជាបានចែងថាអាពាហ៍ពិពាហ៍ត្រូវធ្វើឡើងតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយតែប៉ុណ្ណោះ កាលបើមានភាពផ្ទុយពីនេះ អាពាហ៍ពិពាហ៍នោះជាហេតុនាំឲ្យមានការមោឃភាព។[7]

យោងទៅតាមអនុសញ្ញាអន្តរជាតិស្តីអំពី ការលុបបំបាត់ការរើសអើងគ្រប់រូបភាពប្រឆាំងស្ត្រីភេទបានចែងថា ស្ត្រីមានសិទ្ធិស្មើនឹងបុរសដូចគ្នា ក្នុងជ្រើសរើសដោយសេរីនូវគូស្រករដែលខ្លួនពេញចិត្ត សម្រាប់រៀបអាពាហ៍ពិពាហ៍តាមការយល់ព្រម និងភាពពេញចិត្តរបស់ខ្លួនតែប៉ុណ្ណោះ។

**ឧទាហរណ៍៖** កញ្ញា ក មានអាយុ ២៣ ឆ្នាំ ទើបតែបានបញ្ចប់ការសិក្សាបរិញ្ញាបត្រជំនាញនីតិសាស្ត្រ កញ្ញាត្រូវបានម្តាយរបស់នាងគំរាមឲ្យរៀបការ ជាមួយលោក ខ ដែលនាងមិនមានចិត្តស្រលាញ់ទាល់តែសោះខណៈនាងមានមនុស្សដែលនាងស្រលាញ់រួចទៅហើយ។ ប្រសិនបើនាង មិនយល់ព្រមតាមសំណើររបស់ឪពុកម្តាយនោះទេ ឪពុកម្តាយរបស់នាងនឹងកាត់ការមិនទទួលស្គាល់នាងជាកូនទៀតឡើយ។ ហេតុនេះបង្ហាញឲ្យបានឃើញថាអាពាហ៍ពិពាហ៍នេះ មានលក្ខណៈគំរាមដល់ភាគីនៃចំណងអាពាហ៍ពិពាហ៍។

**ឧទាហរណ៍៖** កញ្ញា ខ មានអាយុ ២៥ ឆ្នាំ បានយល់ព្រមរៀបអាពាហ៍ពិពាហ៍ជាមួយលោក គ ទាំងខ្លួនមិនបានមានភក្តីភាពចំពោះលោក គ បន្តិចណានោះទេ ដោយសារតែមើលឃើញលោក គ គាត់ជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តុមមានភាពស៊ីវិល័យ ដែលខ្លួនស្ម័គ្រចិត្តរៀបការនេះ គឺដោយសារតែនាងសម្លឹងមើលឃើញទ្រព្យតែប៉ុណ្ណោះ អាពាហ៍ពិពាហ៍បែបនេះវាគ្រាន់តែជាការឆបោក។

---

[6] មាត្រា ៤ ច្បាប់ស្តីពីឯកពន្ធភាព និងគ្រួសារ ឆ្នាំ១៩៨៩

[7] មាត្រា ៤៥ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

**ឃ. លក្ខខណ្ឌឯកពន្ធភាព**

អាពាហ៍ពិពាហ៍មួយ ដែលមានលក្ខណៈត្រឹមត្រូវទៅតាមផ្លូវច្បាប់ ជាគោលការណ៍ត្រូវគោរពនូវលក្ខខណ្ឌដែលអាចជាសារវ័ន្ត ពោលគឺចំណងអាពាហ៍ពិពាហ៍ត្រូវតែជាបុរស និងស្ត្រីដែលនៅលីវ ឬ ភាគីម្ខាងនៃចំណងអាពាហ៍ពិពាហ៍ពីមុនត្រូវបានបញ្ចប់ត្រឹមត្រូវទៅតាមផ្លូវច្បាប់ ឲ្យស្របទៅតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់នូវសិទ្ធិពេញទីដល់ប្រជាពលរដ្ឋកម្ពុជាក្នុងការសម្រេចចិត្តជ្រើសរើសគូស្រករ ដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយជាដាច់ខាត។ បានសេចក្តីថា បុគ្គលដែលមានសហព័ទ្ធរួចហើយ ពុំអាចទៅរៀបអាពាហ៍ពិពាហ៍ថ្មីមួយទៀតបានឡើយ ប្រសិនបើចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់បានរំលាយ។ បើមិនដូច្នេះទេ អាពាហ៍ពិពាហ៍នោះនឹងត្រូវចាត់ទុកជាមោឃភាព។[8] ការហាមប្រាមបែបក្នុងគោលបំណងការពារសេចក្តីថ្លៃថ្នូរ និងដើម្បីពង្រឹងភាពសុខដុមរម្យនាដល់សុភមង្គលគ្រួសារ និងធានាការការពារអំពីការរៀបអាពាហ៍ពិពាហ៍មិនឲ្យធ្វើឡើងទៅតាមតែទំនើងចិត្តនោះឡើយ។

**ង. លក្ខខណ្ឌទាក់ទងទៅនឹងទំនាក់ទំនងញាតិរវាងគូរភាគី**

នៅក្នុងក្រមរដ្ឋប្បវេណីបានបញ្ញត្តិអំពីទំនាក់ទំនងរវាងញាតិ ដើម្បីធ្វើការហាមឃាតមិនអនុញ្ញាតឲ្យមានការរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិតផ្ទាល់ ញាតិពន្ធ ព្រមទាំងសាខាញាតិផងដែរ។

ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ រវាងញាតិលោហិតនេះ ត្រូវបានបញ្ញត្តិយ៉ាងច្បាស់នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដោយបានបញ្ញត្តិថា អាពាហ៍ពិពាហ៍មិនអាចធ្វើបានឡើយ រវាងញាតិលោហិតផ្ទាល់ ឬ សាខាញាតិលោហិតក្នុង ៣ (បី) ថ្នាក់ រាប់ទាំងថ្នាក់ទី ៣ (បី) ផងដែរ។[9]

ចំណែកឯ ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធវិញ នៅក្នុងខ្លឹមសារច្បាប់បានធ្វើការញែកចេញជាពីរៈ

- អាពាហ៍ពិពាហ៍ពុំអាចធ្វើបានឡើយ រវាងញាតិនៃខ្សែផ្ទាល់ បញ្ញត្តិនេះត្រូវបានយកមកអនុវត្តផងដែរនៅក្រោយពេលដែលបានបញ្ចប់ទំនាក់ទំនងញាតិពន្ធ ដោយបញ្ញត្តិនៅក្នុងមាត្រា ៩៤១ (ការរលត់ទំនាក់ទំនងញាតិពន្ធ) ឬមាត្រា ១០១៦ (ការកាត់ការនៃសុំកូនពេញលេញ)។
- អាពាហ៍ពិពាហ៍ពុំអាចធ្វើបានឡើយ រវាងសាខាញាតិពន្ធ នៅក្នុង ៣ (បី) ថ្នាក់ រាប់ទាំងថ្នាក់ទី ៣ (បី) ផង។ បញ្ញត្តិនេះត្រូវបានយកមកអនុវត្តដូចគ្នាផងដែរ ក្រោយពេលបានបញ្ចប់ទំនាក់ទំនងញាតិពន្ធតាមបញ្ញត្តិនៃមាត្រា ៩៤១ (ការរលត់ទំនាក់ទំនងញាតិពួន) ខាងលើនេះ។ ប៉ុន្តែបើសហព័ទ្ធណាម្ខាង

[8] មាត្រា ៤៥ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
[9] មាត្រា ៩៥១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ត្រូវបានទទួលមរណភាព សហព័ទ្ធដែលនៅរស់ អាចរៀបអាពាហ៍ពិពាហ៍ជាមួយបុគ្គលដែលធ្លាប់ជាសាខាញាតិពន្ធ នៅក្នុង ៣ (បី) ថ្នាក់បាន។[10]

ដើម្បីបញ្ជាក់បន្ថែមឲ្យកាន់តែច្បាស់លាស់នោះ យើងខ្ញុំសូមធ្វើការលើកឡើងនៅឧទាហរណ៍មួយចំនួនដែលជាទឡ្ហីករណ៍នៃអំណះអំណាងខាងលើនេះ ដើម្បីជាជំនួយផ្នែកស្មារតីឱ្យកាន់តែងាយយល់បន្ថែមទៀត។

**ឧទាហរណ៍៖** ចំពោះ ជីដូ-ជីតា ឪពុក-ម្ដាយ កូន-ចៅ គឺច្បាប់មិនអនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍បាននោះឡើយ។

**ឧទាហរណ៍៖** ចំពោះបងប្អូនបង្កើត (សាខាញាតិថ្នាក់ទី២) ពូមីង និង ក្មួយ (សាខាញាតិថ្នក់ទី៣) ក៏ច្បាប់មិនបានធ្វើការអនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានទេ។

**ឧទាហរណ៍៖** កុមារី ក នៅពេលមានអាយុ ៦ ឆ្នាំ ត្រូវបានអ្នកដំទៃយកទៅចិញ្ចឹមក្នុងនាម សុំកូនពេញលេញ។ក្នុងករណីបែបនេះ ទំនាក់ទំនងញាតិរវាងកុមារី ក និងឪពុកម្ដាយរបស់នាងត្រូវបានបញ្ចប់នេះយោងតាម មាត្រា ១០១៤ នៃក្រមរដ្ឋប្បវេណី។ ក្នុងករណីបែបនេះទោះជា កញ្ញា ក នាងពេញវ័យនីតិភាពក៏ដោយនាងមិនអាចរៀបការជាមួយនឹងឪពុកបង្កើតរបស់នាងបានទេ ហើយក៏មិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយឪពុកចិញ្ចឹមរបស់នាងបានដែរ ទោះបីជាពុំមានការជាប់ខ្សែញាតិអ្វីក៏ដោយ។

### ១.១.២.២ លក្ខខណ្ឌទម្រង់នៃការបង្កើតអាពាហ៍ពិពាហ៍

ជាការពិតណាស់អាពាហ៍ពិពាហ៍មួយដែលមានលក្ខណៈត្រឹមត្រូវទៅតាមច្បាប់ វាមិនមែនត្រឹមតែអនុវត្តទៅតាមលក្ខខណ្ឌគ្រឹះរួចសព្វគ្រប់នោះ ក៏ត្រូវបានគេអាចបានថា វាជាអាពាហ៍ពិពាហ៍ដែលត្រឹមត្រូវពេញលក្ខណៈនោះទេ។ ដូច្នេះហើយអាពាហ៍ពិពាហ៍មួយនេះ វាត្រូវតែការឆ្លងកាត់នូវដំណាក់កាលមួយទៀតដែលគេហៅថា លក្ខខណ្ឌទម្រង់ នៃការបង្កើតអាពាហ៍ពិពាហ៍ ដែលវាជាការបង្ហាញអំពី សញ្ញាណនៃបែបបទនៅក្នុងការអនុវត្តនេះបន្ទាប់ពីគេបានគោរពគ្រឹះរួចចប់សព្វគ្រប់។ ការអនុវត្តបែបនេះ ដោយសារតែច្បាប់បានការពារប្រយោជន៍ទៅដល់ភាគីដែលមានប្រយោជន៍នៅក្នុងចំណងអាពាហ៍ពិពាហ៍នោះតែប៉ុណ្ណោះ។ ហើយក៏មិនមែនក្នុងវត្ថុបំណងចង់ឲ្យមានភាពញៀវញ៉ៃ និងមានភាពស្មុគស្មាញខ្លាំង នៅក្នុងសកម្មភាពនៃការបង្កើតនូវចំណងអាពាហ៍ពិពាហ៍នោះទេ ការធ្វើបែបនេះគ្រាន់តែជាការធានាឲ្យបានថា មានការគោរពទៅតាមច្បាប់តែប៉ុណ្ណោះ។ ដូចនេះដើម្បីឲ្យបានជ្រាបអំពីលក្ខខណ្ឌនេះ យើងខ្ញុំសូមធ្វើការបកស្រាយដូចតទៅ។

[10] មាត្រា ៩៥២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**ក. ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍**

ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ គឺជាគោលការណ៍ត្រូវបានគេធ្វើឡើងនៅឯសាលាឃុំ-សង្កាត់ខាងលំនៅឋានខាងស្រី ដែលមានមន្ត្រីអត្រានុកូលដ្ឋានបានទទួលដឹងឮ ក្នុងនាមជាមន្ត្រីអនុវត្តផងដែរ។ បន្ទាប់ពីបានដាក់ពាក្យរួច មន្ត្រីអត្រានុកូលដ្ឋានលោកនឹងធ្វើការពិនិត្យនូវពាក្យសុំនោះ។ ដើម្បីធ្វើពិនិត្យមើលឲ្យកាន់តែច្បាស់លាស់ថា មានការព្រមព្រៀងដោយសេរី និងមានឆន្ទៈពិតប្រាកដក្នុងការចង់រៀបការ ដោយគ្មានមូលហេតុណាមួយរារាំងដល់អាពាហ៍ពិពាហហ៍នោះទេ។[11]

- **ចំពោះឯកសារចាំបាច់ត្រូវមានដូចជា៖**

- សំបុត្រកំណើតដែលចេញដោយមេឃុំ
- សំបុត្របញ្ជាក់អំពីការគោរពវិធវភាព
- សំបុត្របញ្ជាក់សុខភាពពីពេទ្យ
- ភស្តុតាងនៃការរំលាយអាពាហ៍ពិពាហ៍ការពីមុន (បើធ្លាក់មាន)
- លិខិតបញ្ជាក់ពីភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយរបស់សាមីខ្លួនទាំងពីរ
- លិខិតបញ្ជាក់ពីមន្ត្រីអត្រានុកូលដ្ឋាន (អាចហៅបានថា កិច្ចសន្យាសាមីជនកូនប្រុស-ស្រី)
- លិខិតបញ្ជាក់យល់ព្រមពីឪពុកម្តាយ អាណាព្យាបាល (ករណីអនាគតគូរស្រករជាអនីតិជន)។

បន្ទាប់ពីមន្ត្រីអត្រានុកូលដ្ឋានបានពិនិត្យម្មត់ចត់នូវពាក្យសុំរបស់សាមីខ្លួនទាំងពីររួចហើយ។ ដោយផ្អែកតាមលក្ខខណ្ឌដែលបានគោរពតាម បទបញ្ញត្តិរួចរាល់នោះនាំឲ្យមន្ត្រីអត្រានុកូលដ្ឋានត្រូវចេញប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ដែលត្រូវបានធ្វើការប្រកាសផ្សាយជាសាធារណៈ។

**ខ.ការប្រកាសផ្សាយជាសាធារណៈ**

ប័ណ្ណប្រកាសផ្សាយនេះត្រូវធ្វើការបិទផ្សាយជាសាធារណៈដូចខាងក្រោម៖

- ១ (មួយ) ច្បាប់ត្រូវបិទផ្សាយជាសាធារណៈនៅសាលាឃុំ-សង្កាត់នៅលំនៅឋានខាងនារី
- ១ (មួយ) ច្បាប់ត្រូវរក្សាទុកជាឯកសារនៅសាលាឃុំ-សង្កាត់របស់ខ្លួន
- ១ (មួយ) ច្បាប់ត្រូវផ្ញើរទៅមន្ត្រីអត្រានុកូលដ្ឋានខាងប្រុសដើម្បីបិទនៅលំនៅឋានដ្ឋានខាងប្រុស
- ១ (មួយ) ច្បាប់ត្រូវផ្ញើរជូនសាលាឃុំ-សង្កាត់ខាងប្រុសដើម្បីរក្សាទុកជាឯកសារ។

ប័ណ្ណប្រកាសត្រូវមានចុះព័ត៌មានដូចខាងក្រោមនេះ៖

- នាមត្រកូល-នាមខ្លួន អាយុ ភេទ មុខរបរ និងលំនៅឋាននៃអនាគតប្តីប្រពន្ធ

[11] មាត្រា ២៨ នៃអនុក្រឹតស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០០០

- នាមត្រកូល-នាមខ្លួន អាយុ ភេទ មុខរបរ និងលំនៅឋានរបស់ឪពុកម្តាយនៃអនាគតប្តីប្រពន្ធ បើសិនជាឪពុកម្តាយស្លាប់ត្រូវដាក់ថា (ស្លាប់)។[12]

សូមបញ្ជាក់ថាប័ណ្ណប្រកាសផ្សាយអាពាហ៍ពិពាហ៍ ត្រូវបិទប្រកាសជាសាធារណៈដែលមានរយៈពេលចំនួន ១០ថ្ងៃ នៅមុនពេលរៀបអាពាហ៍ពិពាហ៍។ ដើម្បីឲ្យភាគីដែលមានប្រយោជន៍ក្នុងរឿងនេះ បានទទួលដឹងឮ ហើយអាចប្តឹងជំទាស់អាពាហ៍ពិពាហ៍នេះបាន ប្រសិនបើ មិនមានការយល់ព្រមនឹងអាពាហ៍ពិពាហ៍នោះ។[13] ប្រសិនបើផុតរយៈពេល ១០ថ្ងៃនេះអាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបានកាលបើពុំមាននរណាប្តឹងជំទាស់។ ក៏ប៉ុន្តែក្នុងករណីដែលមានប្តឹងជំទាស់វិញ អាពាហ៍ពិពាហ៍នោះ បើទោះបីជាដល់ពេលតាមការកំណត់ដែលមានរយៈពេល ១០ថ្ងៃខាងលើនេះក៏ដោយ ច្បាប់ពុំអនុញ្ញាឲ្យអាពាហ៍ពិពាហ៍នោះប្រព្រឹត្តឡើងទេ គឺត្រូវតែធ្វើការដោះស្រាយនូវបណ្តឹងជំទាស់ នៃអាពាហ៍ពិពាហ៍នោះឲ្យចប់រួចរាល់ជាមុនសិន។ ដោយយោងទៅតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ។[14]

**គ. ការចុះបញ្ជីអាពាហ៍ពិពាហ៍**

នៅពេលដែលសេចក្តីជូនដំណឹងជាសាធារណៈបានកន្លងផុតទៅ អនាគតប្តីប្រពន្ធទាំងពីររូបត្រូវមានកាតព្វកិច្ចក្នុងការចុះបញ្ជីអាពាហ៍ពិពាហ៍ជាផ្លូវការ នៅចំពោះមុខផ្ទាល់របស់មន្ត្រីអត្រានុកូលដ្ឋានឃុំ-សង្កាត់ នៃលំនៅដ្ឋានខាងស្រី ដោយមានបញ្ជាក់អំពីព័ត៌មានជាមូលដ្ឋានដែលមានការជាប់ពាក់ព័ន្ធនឹងបុរស-នារី ដែលមានបង្ហាញអំពីទិន្នន័យដើម្បីធ្វើសំបុត្រអាពាហ៍ពិពាហ៍ដូចជា៖

- នាមត្រកូល-នាមខ្លួន ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត មុខរបរ របស់បុរសនារី
- នាមត្រកូល-នាមខ្លួន របស់ឪពុកម្តាយទាំងសងខាង
- កាលបរិច្ឆេទនៃការចុះបញ្ជីអាពាហ៍ពិពាហ៍ជាដើម។

កិច្ចសន្យាប្រភេទនេះ ត្រូវបានចុះក្នុងបញ្ជីសៀវភៅអាពាហ៍ពិពាហ៍ ដោយមានការចុះហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋាន នឹងផ្តិតមេដៃទទួលព្រមពីសំណាក់ប្តី-ប្រពន្ធ រួមទាំងមានការចូលរួមពីសាក្សីដឹងឮចំនួន ២ រូប ដែលជាអ្នកមានអាយុគ្រប់គ្រាន់ដែលអាចរៀបអាពាហ៍ពិពាហ៍បាន (នីតិជន) ឬអាចជាអ្នកដែលគាត់មានប្តី-ប្រពន្ធរួចហើយក៏បានដែរ ដោយពួកគាត់ដែលជាសាក្សីនោះគ្រាន់តែធ្វើការផ្តិតមេដៃ បញ្ជាក់នៅក្នុងសំបុត្រអាពាហ៍ពិពាហ៍ផងដែរ។[15]

---

[12] ដកស្រង់ចេញពីសៀវភៅ នីតិរដ្ឋប្បវេណី ទំព័រ៨១ របស់សាស្ត្រាចារ្យ អម សុផាណារ៉ាត ឆ្នាំ២០១៦-២០១៧

[13] មាត្រា ២៩ នៃអនុក្រឹតស្តីពី អត្រានុកូលដ្ឋាន ឆ្នាំ២០០០

[14] មាត្រា ១៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ១៩៨៩

[15] មាត្រា ៣០,៣១ នៃអនុក្រឹតស្តីពី អត្រានុកូលដ្ឋាន ឆ្នាំ២០០០

## ១.២ ទម្រង់នៃការរៀបអាពាហ៍ពិពាហ៍

ជាការពិតនៅក្នុងក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ដែលបានអនុលោមទៅតាម មាត្រា ៩៥៥ ដល់មាត្រា៩៥៧ និងអនុក្រឹតលេខ១០៣អនក្រ.ប ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០ ស្តីពីអត្រានុកូលដ្ឋាន និងអនុក្រឹលេខ៦០ អនក្រ.បកចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការកែសម្រួលមាត្រា ៨ និងមាត្រា ៥៩ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០០ មិនត្រឹមតែបានចង្អុលបង្ហាញអំពីការបង្កើត អាពាហ៍ពិពាហ៍ដែលមានទម្រង់រវាងខ្មែរសុទ្ធសាធ ហើយប្រព្រឹត្តតែនៅលើទឹកដីខ្មែរម្យ៉ាងនោះទេ។ ជាក់ស្តែងនៅ ក្នុងក្រមរដ្ឋប្បវេណី គឺមានមាត្រាមួយចំនួនដែលបានបកស្រាយ អំពីទម្រង់នៃការរៀបដែលមានទម្រង់ជាបញ្ញត្តិ ពិសេស ត្រូវបានយកមកអនុវត្តសម្រាប់អាពាហ៍ពិពាហ៍មួយចំនួនដែលមានធាតុបរទេសចូលរួម ដូចដែរមាននៅ ក្នុងចំណុចខាងក្រោម៖

### ១.២.១ នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ

ជាទូទៅនៅក្នុងទម្រង់ នៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ នឹងពលរដ្ឋខ្មែរ វាមិនមានលក្ខណៈ ស្មុគស្មាញអ្វីឡើយ ចំពោះនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ នឹងពលរដ្ឋខ្មែរ។ យើងនឹងធ្វើការបក ស្រាយឲ្យបានជ្រាបសេចក្តីដូចខាងក្រោមនេះ៖

ដំបូងឡើយបុរសនារីដែលមានបំណងក្នុងការរៀបអាពាហ៍ពិពាហ៍ ត្រូវទៅកាន់មន្ត្រីអត្រានុកូលដ្ឋាននៃ ឃុំ-សង្កាត់នៃលំនៅឋានរបស់នារី។[16] ក្រោយពីបានបំពេញបែបបទក្នុងការរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវទៅតាម លក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់រួចរាល់ មន្ត្រីអត្រានុកូលដ្ឋាននឹងធ្វើការចេញនូវប័ណ្ណប្រកាសផ្សាយអំពី អាពាហ៍ពិពាហ៍ ហើយត្រូវបិទផ្សាយជាសាធារណៈមានរយៈពេលចំនួន ១០ថ្ងៃ នៅលំនៅឋានរបស់បុរសនារី ព្រមទាំងបិទនៅឃុំ-សង្កាត់នៃលំនៅឋានរបស់បុរសនារីទាំងពីរនោះផងដែរ។ ក្រោយពីបានបិទរួចរាល់ត្រឹមត្រូវ ទៅតាមកាលកំណត់ក្នុងអំឡុងពេលនោះ បើមិនមានភាគីណាដែលមានប្រយោជន៍ក្នុងរឿងនេះ មកធ្វើការប្តឹង ជំទាស់ទេអាពាហ៍ពិពាហ៍នេះអាចប្រព្រឹត្តទៅបាន។ ប៉ុន្តែប្រសិនបើមានបណ្តឹងទាស់កើតមានឡើងគេត្រូវធ្វើការ ដោះស្រាយនូវបណ្តឹងទាស់នោះឲ្យបានរួចរាល់សិន ទើបអាចរៀបអាពាហ៍ពិពាហ៍បានជាប្រក្រតី បន្ទាប់មកគូរ ស្វាមី-ភរិយាទាំងពីរត្រូវចុះកិច្ចសន្យានេះ ក្នុងសៀវភៅអាពាហ៍ពិពាហ៍នៅចំពោះមុខផ្ទាល់ មន្ត្រីអត្រានុកូលដ្ឋាន ដោយមានការផ្តិតមេដៃប្តីប្រពន្ធ និងសាក្សីដែលមានអាយុគ្រប់ការចំនួន ២ រូបដែលជាអ្នកធានានិងទទួលដឹងឮ អាពាហ៍ពិពាហ៍នេះ។

[16] មាត្រា ២៨ នៃអនុក្រឹតស្តីពីអត្រានុកូលដ្ឋាន ២០០០

## ១.២.២ នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ ឬរវាងពលរដ្ឋខ្មែរ និង ជនបរទេស នៅបរទេស

ចំពោះការរៀបអាពាហ៍ពិពាហ៍បែបនេះ វាមិនមានលក្ខណៈងាយស្រួលដូចទៅនឹង ទម្រង់នៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរនឹងពលរដ្ឋខ្មែរនោះទេ។ ដោយសារវាអាចមានលក្ខណៈស្មុគស្មាញជាង ពីព្រោះអាពាហ៍ពិពាហ៍បែបនេះមានការទាមទារបំពេញនូវលក្ខខណ្ឌច្រើន ដូចនេះហើយទាមទារឲ្យយើងខ្ញុំដែលជាអ្នកបកស្រាយធ្វើការញែកចេញជាពីរផ្នែក ដើម្បីងាយស្រួលក្នុងការស្រាយនូវចម្ងល់អំពីនីតិវិធីខាងលើនេះ។[17]

❖ **នីតិវិធីច្បាប់នៃប្រទេសដែលសាមីខ្លួនស្នាក់នៅ**

ចំពោះអាពាហ៍ពិពាហ៍ដែលត្រូវបានប្រព្រឹត្ត នៅឯបរទេសបែបនេះ ត្រូវធ្វើឡើងទៅតាមលក្ខខណ្ឌទម្រង់នៃច្បាប់អាពាហ៍ពិពាហ៍នៃប្រទេសនោះ ដែលត្រូវតែមានលក្ខណៈសមស្របទៅនឹងបានទទួលស្គាល់ជាផ្លូវការនៃប្រព័ន្ធច្បាប់នៅកម្ពុជា។ ដូច្នេះលិខិតអាពាហ៍ពិពាហ៍នេះត្រូវយកមកចុះនៅស្ថានទូត ឬ ស្ថានកុងស៊ុលរបស់កម្ពុជាប្រចាំប្រទេសនោះ ឬយកមកចុះបញ្ជីអាពាហ៍ពិពាហ៍នៅសាលាឃុំ-សង្កាត់នៅប្រទេសកម្ពុជា បើសិនជាគូស្វាមី-ភរិយា បានត្រឡប់មកតាំងទីលំនៅក្នុងប្រទេសកម្ពុជាវិញ។ ករណីបែបនេះ ស្ថានទូត ស្ថានកុងស៊ុល ឬមន្ត្រីអត្រានុកូលដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា ត្រូវយកលិខិតថតចម្លងផ្លូវការនោះមករក្សាទុក ហើយត្រូវតែធ្វើការថតចម្លងចេញពីសៀវភៅនូវសំបុត្រអាពាហ៍ពិពាហ៍ថ្មី ផ្ដល់ឲ្យជននោះយកទៅប្រើប្រាស់។[18]

❖ **ចំពោះនីតិវិធីច្បាប់ក្នុងប្រទេសកម្ពុជា**

ចំពោះទម្រង់អាពាហ៍ពិពាហ៍ដែលមានលក្ខណៈបែបនេះហើយ ត្រូវបានអនុវត្តតាមក្របខណ្ឌច្បាប់នៃប្រទេសកម្ពុជា (មត្រា៩៥៧នៃក្រមរដ្ឋប្បវេណី) ត្រូវបានតម្រូវឲ្យធ្វើនៅចំពោះមុខឯកអគ្គរាជទូត ភារធារី ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសនោះ។ ចំណែកឯការជូនដំណឹងជាសាធារណៈស្ដីអំពីការប្រកាសផ្សាយនៃប័ណ្ណអាពាហ៍ពិពាហ៍ត្រូវបានធ្វើឡើងនៅបញ្ជារបស់ស្ថានទូត ឬ ស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាដែលប្រចាំនៅប្រទេសនោះ។[19]

**ឧទាហរណ៍៖** លោក ក និង កញ្ញា ខ គឺជាពលខ្មែរដែលបានធ្វើការងារនៅសហរដ្ឋអាមេរិកជាច្រើនឆ្នាំ ក៏ដូចជាបានរស់នៅឯសហរដ្ឋអាមេរិកជាច្រើនឆ្នាំកន្លងមកហើយដែរ។ យ៉ាងណាមិញប្រសិនសិនណាជាអ្នកទាំងពីរនាក់ មានបំណងក្នុងការរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាគេមានវិធីពីរយ៉ាង៖

[17] មាត្រា ៩៤៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[18] មាត្រា ៣២ នៃអនុក្រឹតស្ដីពីអត្រានុកូលដ្ឋាន ឆ្នាំ២០០០

[19] មាត្រា ៩៥៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

- ត្រូវធ្វើការរៀបចំបែបបទក្នុងការចុះបញ្ជីអាពាហ៍ពិពាហ៍ នៅស្ថានទូតរបស់ប្រទេសកម្ពុជាដែលមានទីតាំងនៅប្រចាំនៅសហរដ្ឋអាមេរិក។
- ចំណែកឯ ជម្រើសមួយទៀតត្រូវរៀបចំបែបបទដើម្បីចុះសំបុត្រអាពាហ៍ពិពាហ៍តាមទៅសហរដ្ឋអាមេរិក។ ក្រោយពីបានទទួលនូវសំបុត្រអាពាហ៍ពិពាហ៍នោះ ឬសេចក្តីចម្លងមកចុះអាពាហ៍ពិពាហ៍ នៅឯស្ថានទូត ឬស្ថានកុងស៊ុលប្រចាំប្រទេសកម្ពុជាដែលមានទីតាំងប្រចាំនៅសហរដ្ឋអាមេរិក ឬបើគូរអនាគតទាំងពីរមករស់នៅប្រទេសកម្ពុជាវិញ ត្រូវយកសំបុត្រអាពាហ៍ពិពាហ៍ ឬសេចក្តីចម្លងមកចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍នៃសាលាសង្កាត់ដែលពួកគេរស់នៅ។

### ១.២.៣ នីតិវិធីក្នុងការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនៅក្នុងប្រទេសកម្ពុជា

នៅក្នុងន័យទូលាយយើងដឹងហើយថាអាពាហ៍ពិពាហ៍ វាគឺជាសេរីភាពមួយដែលកើតចេញអំពីសេចក្តីស្រលាញ់យ៉ាងពិតប្រាកដរវាងចិត្តនឹងចិត្ត ដែលក្តីស្រលាញ់មួយនេះវាមិនបានប្រកាន់នូវពណ៌ សម្បុរ សាសនា ឬជាតិសាសន៍អ្វីឡើយ។ ហេតុនេះហើយទើបទម្រង់អាពាហ៍ពិពាហ៍មួយមានដែល លក្ខខណ្ឌស្រដៀងគ្នាទៅនឹងលក្ខខណ្ឌនៃអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរដែរ ប៉ុន្តែវាមានលក្ខណៈរៀងស្មុគស្មាញបន្តិចដែរដែលតែងជួបប្រទះនោះគេស្គាល់ថា ជានីតិវិធីក្នុងការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស។ ដូច្នេះដើម្បីឲ្យអាពាហ៍ពិពាហ៍ដែលមានទម្រង់បែបនេះ វាមានលក្ខណៈត្រឹមត្រូវទៅតាមនីតិវិធីច្បាប់បានល្អប្រសើរនោះ យើងសូមធ្វើការលើកយកនូវខ្លឹមសារមួយចំនួនមកបញ្ជាក់ជូន ដើម្បីជាការបានសិក្សាទាំងអស់គ្នា។ ដោយយោងទៅតាមអនុក្រឹតរបស់រាជរដ្ឋាភិបាលលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៨ ដែលស្តីអំពីទម្រង់បែបបទនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនៅប្រទេសកម្ពុជា ដែលមានគោលដៅទប់ស្កាត់ការជួញដូរស្ត្រីខ្មែរទៅកាន់បរទេស ក្នុងរូបភាពការរៀបអាពាហ៍ពិពាហ៍ ដោយសាររយៈពេលកន្លងមកយើងឃើញមានការការជួញដូរស្ត្រី និងកុមារីជាច្រើនយកទៅលក់ ឬជួញក្នុងរូបភាពអាពាហ៍ពិពាហ៍ដូចដែលបានជួបប្រទះបែបនេះកន្លងមកមាន តៃវ៉ាន់ កូរ៉េខាងត្បូង និងម៉ាឡេស៊ី តាមរយៈអាពាហ៍ពិពាហ៍ក្លែងក្លាយជាដើម។ ដូចនេះយើងសូមលើកឡើងនូវលក្ខខណ្ឌខ្លះៗ ដើម្បីយកមកបង្ហាញដែលចែកចេញជាពីរដំណាក់កាលគឺ ៖ ដំណាក់កាលរដ្ឋបាល និងដំណាក់កាលចុះបញ្ជីនៃអាពាហ៍ពិពាហ៍។

❖ **ដំណាក់កាលរដ្ឋបាល**

សាមីខ្លួនដែលជាជនបរទេស ត្រូវដាក់ពាក្យដើម្បីសុំរៀបអាពាហ៍ពិពាហ៍តាមរយៈការស្ថានទូតរបស់ខ្លួន និងបានបំពេញបែបបទទៅកាន់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ដោយត្រូវធ្វើការភ្ជាប់មកជានូវសំណុំឯកសារដូចខាងក្រោមៈ

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍
- ឯកសារថតចម្លងនៃលិខិតឆ្លងដែនរបស់សាមីខ្លួនដែលមានសុពលភាព
- លិខិតបញ្ជាក់នូវភាពលីវ ឬពោះម៉ាយ ឬមេម៉ាយដោយសមត្ថកិច្ចនៃប្រទេសសាមីខ្លួន
- លិខិតបញ្ជាក់សុខភាពចេញដោយសមត្ថកិច្ចនៃប្រទេសកម្ពុជា
- លិខិតថ្កោលទោសដែលចេញដោយប្រទេសសាមីជនបរទេស
- លិខិតបញ្ជាក់មុខរបរពិតប្រាកដដែលចេញដោយសមត្ថកិច្ចនៃប្រទេសសាមីខ្លួន។

បន្ទាប់ពីមានលិខិតខាងលើទាំងអស់នេះហើយ ក្រសួងការបរទេសនឹងធ្វើការយកមកពិនិត្យអំពីនីត្យានុកូលភាពនៃឯកសារទាំងនោះយ៉ាងល្អិតល្អន់ថា តើវាមានភាពត្រឹមត្រូវ និងគ្រប់គ្រាន់ដែរឬទេ? ប្រសិនជាមានភាពខុសឆ្គង ឬកែតម្រូវនៅត្រង់ចំណុចណានិងផ្តល់នូវយោបល់លើសំណុំឯកសារ ហើយជូនដំណឹងទៅកាន់សាមីខ្លួនជនបរទេសក្នុងរយៈពេលយ៉ាងយូរចំនួន ៥ថ្ងៃការងារព្រមទាំងជូនដំណឹងទៅស្ថានទូត ឬស្ថានកុងស៊ុលវិញតំណាងវិញផងដែរ។ ក្រោយមកទៀត ក្រសួងការបរទេសនឹងបញ្ជូនបែបបទនេះទៅកាន់ក្រសួងមហាផ្ទៃធ្វើការចាត់ចែងតាមនីតិវិធីបន្ទាប់មកក្រសួងនឹងធ្វើការជូនដំណឹងអំពីការសុំរៀបអាពាហ៍ពិពាហ៍នេះទៅកាន់ខាងមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ-សង្កាត់នៃលំនៅឋានអចិន្ត្រៃយ៍របស់សាមីខ្លួនជាពលរដ្ឋខ្មែរ។

❖ **ដំណាក់កាលនៃការចុះបញ្ជីអាពាហ៍ពិពាហ៍**

សាមីខ្លួនដែលជាជនបរទេស ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ទៅកាន់មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ-សង្កាត់នៃលំនៅឋានរបស់សាមីខ្លួនជាពលរដ្ឋខ្មែរ។ ស្របពេលជាមួយគ្នានេះដៃគូដែលជាសាមីខ្លួនជាពលរដ្ឋខ្មែរក៏ត្រូវដាក់ពាក្យរៀបអាពាហ៍ពិពាហ៍ ទៅកាន់លំនៅឋាននៃសាលាឃុំ-សង្កាត់ខាងលំនៅឋានរបស់ខ្លួនដែរ ដោយភ្ជាប់ជាមួយនូវឯកសារផ្សេងៗ។ ក្រោយពីបានឃើញនូវឯកសារខាងលើនេះហើយ មន្ត្រីអត្រាដ្ឋាននៃឃុំ-សង្កាត់ខាងលំនៅឋានរបស់សាមីខ្លួនពលរដ្ឋខ្មែរត្រូវពិនិត្យ និងសម្រេចលើពាក្យស្នើសុំរបស់សាមីទាំងពីរនាក់ក្នុងរយៈពេលចំនួន ៣ថ្ងៃការងារ។[20]បើពិនិត្យមើលឃើញថាលិខិត ឬឯកសារទាំងនោះមានភាពត្រឹមត្រូវទៅតាមផ្លូវច្បាប់ហើយ វានឹងនាំឲ្យមន្ត្រីអត្រានុកូលដ្ឋានត្រូវចេញនូវប័ណ្ណប្រកាសអាពាហ៍ពិពាហ៍មានចំនួន ៥ច្បាប់ ដោយមាន

[20] មាត្រា ១០ នៃអនុក្រឹតស្តីពីទម្រង់នៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៨

ការបិទរូបថតរបស់សាមីជនទាំងពីរនាក់នៅខាងលើផ្នែកខាងស្តាំ។ ចំពោះប័ណ្ណប្រកាសអាពាហ៍ពិពាហ៍នេះមានត្រូវបិទផ្សាយក្នុងរយៈពេល ១០ថ្ងៃ ដោយប័ណ្ណមួយត្រូវរក្សាទុកនៅសាលាឃុំ-សង្កាត់ ចំណែកឯប័ណ្ណដែលមាននៅសេសសល់ត្រូវបានបិទនៅទីតាំងមួយចំនួនដូចជា៖

- ស្ថានទូត ឬស្ថានកុងស៊ុល ឬស្ថានតំណាងនៃប្រទេសសាមីខ្លួនជនបរទេសប្រចាំ នៅព្រះរាជាណាចក្រកម្ពុជា
- លំនៅឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ
- នៅសាលាឃុំ-សង្កាត់នៃលំនៅឋានរបស់សាមីខ្លួនពលរដ្ឋខ្មែរ
- នៅលំនៅឋាន ឬទីកន្លែងស្នាក់នៅរបស់សាមីខ្លួនជនបរទេស (ប្រសិនបើមាន)។

ចំណុចដូចដែរបានរាប់រៀបខាងលើនេះ វាបានបង្ហាញយ៉ាងច្បាស់ថា អាពាហ៍ពិពាហ៍មួយ ដែលមានភាពស្របច្បាប់ នឹងត្រឹមត្រូវទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដោយស្របទៅតាមលក្ខខណ្ឌច្បាប់ និងទំនៀមទម្លាប់ប្រពៃណីដ៏ល្អរបស់សង្គមជាតិ នឹងបានឆ្លុះបញ្ចាំងអំពីសេចក្តីថ្លៃថ្នូររបស់ជាតិសាសន៍យើង។ យ៉ាងណាមិញនោះ ប្រសិនបើមានអាពាហ៍ពិពាហ៍ណាមួយដែលមិនបានគោរព និងអនុវត្តទៅតាមលក្ខខណ្ឌខាងលើនេះទេ វាអាចជាកត្តាដែលនាំឲ្យអាពាហ៍ពិពាហ៍នោះ ត្រូវបានប្រឈមមុខទៅនឹង មោឃភាព ឬអាចឈានទៅដល់ការលុបចោលតែម្តង ដែលវាអាស្រ័យទៅលើវិការៈនីមួយៗ ដូចដែលកើតមានឡើងក្នុងនៅក្នុងចំណងអាពាហ៍ពិពាហ៍នោះ ដែលអាចកើតមានឡើងក្នុងចំណងអាពាហ៍ពិពាហ៍នោះ ដែលយើងខ្ញុំនឹងលើកយកមកបកស្រាយនៅជំពូកជាបន្តបន្ទាប់។

# ជំពូកទី២
# មោឃភាពនៃអាពាហ៍ពិពាហ៍

## ២.១ សញ្ញាណគតិយុត្តនៃមោឃភាពកិច្ចសន្យា

ឆ្លងតាមរយៈការសិក្សាកន្លងមកយើងដឹងហើយថា មូលហេតុដែលនាំឲ្យកិច្ចសន្យាមួយត្រូវបានអស់នូវសុពលភាព ឬគ្មានសុពលភាពតែម្តងនោះ គឺដោយសារតែវាមានវិការៈណាមួយបានកើតមានឡើងនៅក្នុងកិច្ចសន្យានោះជាមិនខាន។ វិការៈនោះហើយដែលជាហេតុដ៏សំខាន់ក្នុងការលើកយកជាមូលហេតុក្នុងការមោឃភាព នៃកិច្ចសន្យានោះ។

### ២.១.១ និយមន័យនៃមោឃភាព

នៅក្នុងសន្ទានុក្រមនៃក្រមរដ្ឋប្បវេណី គេបានឲ្យនិយមន័យនៃពាក្យថា មោឃភាព ជាពីរផ្សេងគ្នាគឺ (១) ជាភាពពុំមានអានុភាពតាមផ្លូវច្បាប់ នៃសកម្មភាពគតិយុត្តដែលផ្ទុយនឹងបញ្ញត្តិអំពីនីតិវិធីបណ្តឹង និង (២) គឺជាទណ្ឌកម្មដែលប្រកាសដោយចៅក្រមលុបបំបាត់ចោលជាប្រតិសកម្មនូវលិខិតគតិយុត្ត មិនបានបំពេញលក្ខខណ្ឌដែលច្បាប់កំណត់ ឬសកម្មភាពណាមួយដែលផ្ទុយពីនីតិវិធីនៃច្បាប់។[21] យ៉ាងណាមិញសម្រាប់ការមោឃភាពនូវកិច្ចសន្យា គឺជាការបដិសេធចំពោះការយល់ព្រមនៃការអានុភាពនៃកិច្ចសន្យានោះដោយយោងទៅតាមសកម្មភាពដែលបានបង្កើតឡើងនោះមានការបង្ហាញនូវឆន្ទៈមិនពិតដូចដែលបានចែងនៅក្នុងមាត្រា៣៥៣ ឬអត្ថន័យនៃកិច្ចសន្យានោះវាមានភាពផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ ឬផ្ទុយពីសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អរបស់សង្គមដូចដែលបានចែងក្នុងមាត្រា៣៥៤ ឬផ្ទុយពីទម្រង់ដែលច្បាប់បានកំណត់ជាដើម។ យោងតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបញ្ជាក់យ៉ាងច្បាស់ថា កិច្ចសន្យាដែលត្រូវបានមោឃភាព វានឹងនាំឲ្យកិច្ចសន្យានោះគ្មានសុពលភាពតាំងពីដំបូង។ ចំពោះការអះអាងក្នុងការមោឃភាពផ្អែកតាមមាត្រា៣៥៧ នៃក្រមបានធ្វើការកំណត់ថា ជនណាក៏ដោយ ក៏អាចអះអាងពីមោឃភាពបានដែរ ដោយមិនមានការកំណត់អំពីអាជ្ញាយុកាលនោះឡើយ។[22]

### ២.១.២ មូលហេតុនៃមោឃភាពកិច្ចសន្យា

ទោះបីជាភាគីនៃកិច្ចសន្យាបានបង្ហាញនូវឆន្ទៈដោយពុំមានវិការៈក៏ដោយ ក៏កិច្ចសន្យាមួយនេះត្រូវបានចាត់ទុកជាមោឃៈភាពបានដែរ ដែលជាហេតុនាំឲ្យគេចាត់ទុកថាគ្មានអត្ថិភាពនៃកិច្ចសន្យាតាំងពីដំបូងប្រសិនបើមានមូលហេតុដូចជា ការបង្ហាញឆន្ទៈមិនពិត ឬ អត្ថន័យនៃកិច្ចសន្យាផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ ឬមាន

[21] សន្ទានុក្រមលេខ១២៥ នៃក្រមរដ្ឋប្បវេណី

[22] មាត្រា ៣៥៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ការផ្ទុយពីសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អរបស់សង្គម ឬទម្រង់នៃកិច្ចសន្យាដែលបានបង្កើតឡើងនោះវាមិនសមស្របទៅតាមបញ្ញត្តិដែលច្បាប់បានកំណត់។

### ២.១.២.១ ការបង្ហាញឆន្ទៈមិនពិត

ការបង្ហាញឆន្ទៈមិនពិត វាគឺជាការបង្ហាញឆន្ទៈនៅក្នុងកិច្ចសន្យាដែលមានអត្ថន័យខុសពីឆន្ទៈពិតប្រាកដរបស់ភាគីម្ខាងទៀតនៃកិច្ចសន្យានោះ ដោយមានការឃុបឃិតជាមួយនឹងភាគីម្ខាងទៀតនៃកិច្ចសន្យា ទាំងដឹងថាខុសឆន្ទៈខាងក្នុង ហើយកិច្ចសន្យាដែលត្រូវបានបង្កើតឡើងនោះ វាមានរូបភាពខាងក្រៅស្របច្បាប់។ កិច្ចសន្យាដែលមានសភាពបែបនេះត្រូវចាត់ទុកថា មោឃៈ។[23]

យោងតាមស្មារតីនៃខ្លឹមសារច្បាប់ខាងលើនេះ កិច្ចសន្យាមួយដែលត្រូវបានធ្វើឡើងដោយការបង្ហាញនូវឆន្ទៈមិនពិតនេះ ដើម្បីអាចអះអាងពីមោឃៈនេះបានត្រូវគោរពនូវលក្ខខណ្ឌចំនួនបួនដែលរួមមានដូចជា៖

(១) ត្រូវមានអត្ថិភាពនៃការបង្ហាញឆន្ទៈ

(២) ឆន្ទៈដែលបានបង្ហាញខាងក្រៅមិនត្រូវគ្នាទៅនឹង ការបង្ហាញឆន្ទៈខាងក្រៅ

(៣) អ្នកបង្ហាញឆន្ទៈដឹងថាឆន្ទៈដែលបានលើកឡើងនោះ មិនត្រូវគ្នានឹងឆន្ទៈខាងក្នុង និង

(៤) ការឃុបឃិតគ្នារវាងភាគីនៃកិច្ចសន្យាជាដើម។

**ឧទាហរណ៍៖** លោក ក បានធ្វើកិច្ចសន្យាមួយអំពីការលក់នូវ កសិដ្ឋានចិញ្ចឹមសត្វរបស់ខ្លួនទៅឲ្យ លោក ខ ដែលជាអ្នកជិតខាងរបស់ខ្លួននៅក្នុងតម្លៃមួយយ៉ាងទាបបំផុតហើយនៅពេលណាមួយសមស្របលោក ខ ត្រូវតែប្រគល់នូវកសិដ្ឋាននេះឲ្យមកកាន់ខ្លួនវិញ។ លោក ក និងលោក ខ គឺអ្នកទាំងពីរនាក់នេះមិនមានឆន្ទៈក្នុងការទិញលក់ពិតប្រាកដទេ ដែលវាគ្រាន់តែជាការឃុបឃិតគ្នារវាងពួកគេទាំងពីរនាក់តែប៉ុណ្ណោះ ក្នុងវត្ថុបំណងមួយដើម្បីគេចវេសពីកាតព្វកិច្ចសងបំណល់ទៅម្ចាស់បំណល់ដែលជាលោក គ តែប៉ុណ្ណោះ ដែលលោក គ ជាម្ចាស់បំណុលរបស់លោក ក ដោយលោក ក នេះឯងមិនមានលទ្ធភាពក្នុងការសងនូវបំណុលដល់លោក គ ទេ ទើបលោក ក បានសម្រេចជិតធ្វើកិច្ចសន្យាលក់កសិដ្ឋាននោះឲ្យទៅ លោក ខ តែម្ដង។

ដូច្នេះដើម្បីសិក្សាថា ការលើកឡើងពីមោឃភាពកិច្ចសន្យាលក់ទិញកសិដ្ឋាននោះបាន ដែលលោក ក និង លោក ខ បានធ្វើជាមួយគ្នានោះ ដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិតបាន ឬយ៉ាងណានោះ គេត្រូវសិក្សា និងធ្វើការពិនិត្យទៅលើលក្ខខណ្ឌដូចខាងក្រោមនេះ៖

- លោក ក បានបង្ហាញឆន្ទៈក្នុងការលក់កសិដ្ឋានចិញ្ចឹមសត្វទៅកាន់លោក ខ (មានអត្ថិភាពនៃការបង្ហាញឆន្ទៈស្របតាមលក្ខខណ្ឌទី១ខាងលើដែរបានលើឡើង)។

[23] មាត្រា ៣៥៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

- ដោយផ្អែកតាមការលើកឡើងនូវឧទាហរណ៍ខាងលើ លោក ក គ្មានឆន្ទៈទាល់តែសោះក្នុងការលក់កសិដ្ឋានរបស់ខ្លួនទៅឲ្យលោក ខ ។ ដោយឆន្ទៈពិតប្រាកដរបស់លោក ក គឺខ្លួនចង់រក្សាទុកកសិដ្ឋាននោះជាកម្មសិទ្ធិរបស់ខ្លួនដដែល (ឆន្ទៈដែលបានបង្ហាញចេញមកខាងក្រៅមិនត្រូវគ្នានឹងឆន្ទៈខាងក្នុងស្របតាមលក្ខខណ្ឌទី២ខាងលើ)។
- លោក ក បានដឹងច្បាស់ពីការណ៍បង្ហាញឆន្ទៈមិនពិតរបស់ខ្លួន ព្រោះគាត់ដឹងថាផ្ទាល់មិនមានឆន្ទៈក្នុងការលក់កសិដ្ឋាននោះទៅឲ្យលោក ខ ទេ ការដែលធ្វើបែបនេះគឺដើម្បីគេចវេសពីការរឹបអូសពីសំណាក់ម្ចាស់បំណុលតែប៉ុណ្ណោះ (អ្នកបង្ហាញឆន្ទៈដឹងថាឆន្ទៈដែលបានបង្ហាញនេះមិនត្រូវគ្នានឹងឆន្ទៈខាងក្នុង ស្របតាមលក្ខខណ្ឌទី៣ខាងលើ)។
- លោក ខ ដែលជាអ្នកជិតខាងនោះ ក៏បានដឹងពីវត្តមាននៃការបង្ហាញឆន្ទៈមិនពិតរបស់លោក ក ដែរ ព្រោះលោក ខ បានព្រមទិញកសិដ្ឋាននោះក្នុងតម្លៃទាបបំផុត និងខ្លួនព្រមប្រគល់ទៅឲ្យលោក កវិញនៅពេលណាសមស្របជាមួយនឹងថ្ងូរណាមួយពីលោក ក (នេះបញ្ជាក់បានថាកិច្ចសន្យាដែលលើកឡើងខាងលើនេះជាការឃុបឃិតគ្នាទាំងស្រុង ស្របតាមលក្ខខណ្ឌទី៤ខាងលើនេះ)។

ដូច្នេះតាមរយៈការលើកឡើងនូវឧទាហរណ៍ខាងលើបានសបញ្ជាក់បានថា លក្ខខណ្ឌទាំងបួននៃការបង្ហាញមិនពិត វាត្រូវបានបំពេញ។ ដូចនេះគេអាចលើកឡើងពីការមោឃភាពនៃកិច្ចសន្យានេះបាន ដោយផ្អែកទៅតាមឆន្ទៈមិនពិតប្រាកដបាន ចំពោះកិច្ចសន្យាលក់ទិញរវាងលោក ក និងលោក ខ បាន។

**២.១.២.២ អត្ថន័យនៃកិច្ចសន្យាផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ**

ជាទូទៅបទបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីបានផ្ដល់សិទ្ធិទៅឲ្យភាគីនៃកិច្ចសន្យាអាចព្រមព្រៀង ឬធ្វើការកំណត់នូវអត្ថន័យនៃកិច្ចសន្យាបានដោយសេរី តាមឆន្ទៈព្រមព្រៀងរបស់ភាគី ឬហៅបានម្យ៉ាងទៀតថា ជាគោលការណ៍ស្វ័យភាពបុគ្គលឯកជនដែលជាគោលការណ៍មូលដ្ឋានមួយនៅក្នុងក្រមរដ្ឋប្បវេណី។[24] ។ ទោះបីជាមានការបង្ហាញឆន្ទៈរបស់ភាគីទាំងពីរត្រូវបានធ្វើឡើងដោយគ្មានមូលហេតុ នៃមោឃៈភាព ឬការលុបចោលក៏ដោយ ក៏កិច្ចសន្យាចាត់ទុកជាមោឃៈបានដែរ ប្រសិនបើអត្ថន័យនៃកិច្ចសន្យានោះបានផ្ទុយនឹងបញ្ញត្តិដែលអនុវត្តបង្ខំ ឬសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ។ ផ្សាភ្ជាប់នឹងគ្នានេះដែរបញ្ញត្តិអំពីការអនុវត្តដោយបង្ខំ គឺជាបញ្ញត្តិមួយដែលបានធ្វើការបដិសេធអានុភាព នៃសកម្មភាពដែលបានផ្ទុយនឹងបញ្ញត្តិនោះ។ គំនិតដែលផ្ទុយទៅនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ គឺជាកម្រិតទំហំនៃសេរីភាពក្នុងការធ្វើកិច្ចសន្យា។ កិច្ចសន្យាដែលត្រូវបាន

[24] មាត្រា ៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

បង្កើតឡើងដោយផ្ទុយទៅនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ កិច្ចសន្យានោះត្រូវបានចាត់ទុកជាមោឃៈ។ ដើម្បីងាយស្រួលនៅក្នុងការលើលឡើងខាងលើនេះ យើងខ្ញុំនឹងទាញយកនូវការឧទាហរណ៍មួយចំនួនជាការគូសបញ្ជាក់ទៅដល់ការលើឡើងខាងលើនេះឲ្យមានលក្ខណៈកាន់តែល្អប្រសើរបន្ថែមទៀត។

**ឧទាហរណ៍៖** ចំពោះកិច្ចសន្យាខ្ចីបរិភោគ យើងឃើញថាប្រសិនណាជាភាគីបានកំណត់នូវអត្រាការប្រាក់លើសពីអត្រាការប្រាក់ដែលច្បាប់បានកម្រិតនោះ កិច្ចសន្យានៃភាគដែលលើសការកម្រិតនៃអត្រាការប្រាក់នោះ ត្រូវបានមោឃៈហើយអ្នកខ្ចីគេមានករណីកិច្ចសងចំពោះការប្រាក់ដែលត្រូវបានគណនាតាមអត្រាការប្រាក់ដែលត្រូវបានកម្រិតតែប៉ុណ្ណោះ។

**ឧទាហរណ៍៖** ចំពោះអាពាហ៍ពិពាហ៍មួយដែលត្រូវបានប្រព្រឹត្តឡើងដោយមានការភាន់ច្រឡំលើមនុស្ស ការបង្ខំ និងមានមូលហេតុផ្សេង ទៀតក៏ត្រូវបានអនុញ្ញាតឲ្យប្ដឹងក្នុងការធ្វើមោឃភាពបានដែរប្រសិនបើអាពាហ៍ពិពាហ៍នោះវាបានផ្ទុយពីបញ្ញត្តិអនុវត្តដោយបង្ខំ។

**ឧទាហរណ៍៖** បន្ថែមពីនេះទៀត ជាបញ្ញត្តិអនុវត្តដោយបង្ខំដូចគ្នាផងដែរ ចំពោះបញ្ញត្តិនៃច្បាប់ការងារដែលបានកំណត់អំពីកម្រិតអតិបរមានៃម៉ោងធ្វើការប្រចាំសប្ដាហ៍ ហើយប្រសិនបើនិយោជក និងកម្មករនិយោជិតបានចុះកិច្ចសន្យាដែលបានបញ្ចូលម៉ោងធ្វើការហួសពីកម្រិតអតិបរមានោះ កិច្ចសន្យានោះត្រូវចាត់ទុកជាមោឃៈដោយសារតែបានបំពានបញ្ញត្តិអនុវត្តដោយបង្ខំទាក់ទងទៅនឹងម៉ោងបំពេញការងារ។

**២.១.២.៣ អត្ថន័យនៃកិច្ចសន្យាផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ**

ពាក្យថាសណ្ដាប់ធ្នាប់សាធារណៈ នៅត្រង់នេះគឺសំដៅទៅលើសណ្ដាប់ធ្នាប់ប្រទេស ឬសង្គម ចំណែកឯពាក្យថា ទំនៀមទម្លាប់ល្អនៅត្រង់នេះវិញ វាសំដៅទៅលើគោលគំនិតជាសីលធម៌ទូទៅនៅក្នុងសង្គម។ ដូចនេះឲ្យតែមានកិច្ចសន្យាដែលមានអត្ថន័យបំពានទៅនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អនាំឲ្យកិច្ចសន្យានោះត្រូវបានចាត់ទុកជាមោឃៈ។ បើទោះបីជាក្រមរដ្ឋប្បវេណីបានបញ្ញត្តិ អំពីគោលការណ៍ស្វ័យភាពបុគ្គលឯកជនដែលជាគោលការណ៍មូលដ្ឋានមួយ។ ដោយផ្ដល់ឲ្យភាគីនៃកិច្ចសន្យាមានសេរីភាពក្នុងការសម្រេចពីកម្មវត្ថុនៃខ្លឹមសារដែលមានក្នុងកិច្ចសន្យារបស់ពួកគេក៏ដោយ ក៏ខ្លឹមសារទាំងនោះត្រូវតែគោរពនូវព្រំដែន ព្រមទាំងមិនអាចបំពានទៅនឹងសីលធម៌ ឬទំនៀមទម្លាប់ល្អរបស់សង្គមបានដែរ។ ពីព្រោះថា បើច្បាប់អនុញ្ញាតឲ្យកិច្ចសន្យាដែលមានខ្លឹមសារ ឬគោលគំនិតបានប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អមានអានុភាពក្នុងការអនុវត្តបានដែរនោះ វានឹងនាំឲ្យមានភាពអនាធិតេយ្យនៅក្នុងសង្គមជាក់ជាមិនខាន។

**ឧទាហរណ៍៖** គ្រួសារលោក ក គាត់បានជំពាក់ប្រាក់ លោក ខ ជាច្រើននឹងយូរមកហើយ តែដោយសារស្ថានភាព ក៏ដូចជាកម្រិតជីវភាពរបស់គ្រួសារលោក ក មិនអាចមានលទ្ធភាពក្នុងការសងប្រាក់បាន នៅពេលដែលថ្ងៃកំណត់នៃការសងប្រាក់បានមកដល់នោះ។ លោក ក គាត់ពុំមានលទ្ធភាពសងទេ ទើបលោក កបាន

សម្រេចចិត្តយកកូនស្រីរបស់ខ្លួនទៅឲ្យបម្រើគេហដ្ឋានរបស់លោក ខ ដោយមិនទទួលបានកម្រៃជាមួយថ្នូលនៃការសង់ប្រាក់។ ទោះបីជាកិច្ចសន្យានោះភាគីទាំងពីរមានឆន្ទៈទទួលព្រមទាំងសងខាងក៏ដោយ ក៏កិច្ចសន្យាមួយនេះត្រូវបានមោឃភាពបានដែរ ពីព្រោះវាបានជិះឥទ្ធិពលអាក្រក់ទៅដល់សង្គមជាតិជាខ្លាំង ពិសេសប៉ះពាល់ទៅដល់ទំនៀមទម្លាប់ល្អរបស់សង្គម។

**ឧទាហរណ៍៖** លោក ក ជាជនក្រីក្រម្នាក់ បានធ្វើកិច្ចសន្យាលក់ភ្នែក ឲ្យទៅលោក ខ ក្នុងតម្លៃមួយថ្លៃដែលអាចឲ្យលោក ក រស់នៅបានស្រណុកសុខស្រួលពេញមួយជីវិតក៏ដោយ។ កិច្ចសន្យាបែបនេះត្រូវបានចាត់ទុកថាមោឃៈ ព្រោះវាបានធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ម្យ៉ាងវិញទៀតច្បាប់មិនបានអនុញ្ញាតឲ្យមានការជួញដូរលើផ្នែកណាមួយនៃសារពាង្គកាយរបស់មនុស្សឡើយ។

### ២.១.២.៤ កិច្ចសន្យាផ្ទុយ នឹងទម្រង់ដែលបានទាមទារដោយច្បាប់

ជាគោលការណ៍ កិច្ចសន្យាមួយដែលកើតមានឡើង និងមានអានុភាពបាន លុះត្រាតែសំណើរ និងស្វីការត្រូវគ្នា។ ទោះបីជាយ៉ាងនេះក្តីក៏មានកិច្ចសន្យាមួយចំនួនតម្រូវឲ្យធ្វើឡើងតាមទម្រង់ដែលបានកំណត់ជាក់លាក់ ទើបអាចក្លាយទៅជាកិច្ចសន្យាដែលមានអានុភាពបាន។ ដូច្នេះប្រសិនណាបើ កិច្ចសន្យានោះមិនបានគោរពទៅតាមលក្ខខណ្ឌតម្រូវទេ កិច្ចសន្យានោះនឹងមិនមានសុពលភាពបានឡើយ។

**ឧទាហរណ៍៖** លោក ក និង លោកស្រី ខ បានរៀបអាពាហ៍ពិពាហ៍នឹងគ្នារួចរាល់ក៏បាននាំគ្នាទៅចុះសំបុត្រអេតាស៊ីវិលនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានដោយមានសាក្សីចំនួនពីររូប ដែលច្បាប់បានតម្រូវ។ តែយ៉ាងណាមិញអ្នកទាំងពីរដែលជាប្តី ប្រពន្ធខាងលើបាននាំយកសាក្សីចំនួនពីររូបទៅសាលាសង្កាត់ក៏ពិតមែនតែក្នុងចំណោមសាក្សីទាំងពីររូបនោះមានម្នាក់ជាអនីតិជន ដែលនេះបានបញ្ជាក់ថាសកម្មភាពនោះបានផ្ទុយទៅនឹងទម្រង់ដែលច្បាប់ទាមទារបាត់ទៅហើយ ពីព្រោះជាថាជាគោលការណ៍សាក្សីដែលមានសិទ្ធិគ្រប់គ្រាន់ក្នុងការធានាអំពីការចុះអេតាស៊ីវិលត្រូវតែមានវ័យនីតិភាពដែលអាចរៀបអាពាហ៍ពិពាហ៍បាន។ ដូច្នេះលោក ក និង លោកស្រី ខ មិនបានគោរពនូវទម្រង់ដែលច្បាប់បានកំណត់ទេជាហេតុនាំឲ្យសកម្មភាពអ្នកទាំងនេះត្រូវបានធ្វើការមោឃៈ។

**ឧទាហរណ៍៖** លោក ក និង លោក ខ បានបង្កើតកិច្ចសន្យាដឹកជញ្ជូននូវគ្រឿងញៀនជាមួយគ្នា។ ដោយធ្វើការដឹកជញ្ជូននេះត្រូវបានកំណត់ថា ថ្លៃដឹកជញ្ជូននេះត្រូវតែបានកំណត់យ៉ាងច្បាស់លាស់នៅក្នុងកិច្ចសន្យានោះ។ ទោះបីជាភាគីទាំងពីរបានសម្រេចជាមួយគ្នាបែបនេះក៏ដោយ បើទោះជាមានភាគីណាមួយមិនបានអនុវត្តតាម ក៏មិនជាបញ្ហាអ្វីនោះឡើយ ដោយសារតែកិច្ចសន្យានេះត្រូវបានមោឃភាពរួចបាត់ទៅហើយ ដោយផ្អែកទៅលើកម្មវត្ថុនៃកិច្ចសន្យានេះ (ការដឹកជញ្ជូនគ្រឿងញៀន) ខុសទៅនឹងបញ្ញត្តិច្បាប់។

### ២.១.២.៥ ការតំណាងដោយគ្មានសិទ្ធិ

ការតំណាង គឺជារបបមួយដែលទទួលស្គាល់នូវអានុភាពនៃសកម្មភាពគតិយុត្តត្រូវមានទៅលើម្ចាស់សិទ្ធិ ក្នុងករណីដែលម្ចាស់សិទ្ធិមានទំនាក់ទំនងជាក់លាក់ជាមួយបុគ្គលដទៃទៀត ហើយបុគ្គលនោះបង្ហាញថា ការបង្ហាញនូវឆន្ទៈ ឬការទទួលយកការបង្ហាញឆន្ទៈនោះធ្វើឡើងសម្រាប់ម្ចាស់សិទ្ធិ។ ដោយសិទ្ធិតំណាងនេះ វាកើតឡើងដោយកិច្ចសន្យារវាងម្ចាស់សិទ្ធិ និងអ្នកតំណាង ឬដោយបញ្ញត្តិនៃច្បាប់។[25] យ៉ាងណាមិញប្រសិនបើមានការតំណាងណាមួយដោយគ្មានសិទ្ធិ ឬយើងអាចនិយាយបានថាម្ចាស់សិទ្ធិពុំបានប្រគល់សិទ្ធិណាមួយឡើយ ស្រាប់តែមានបុគ្គលណាមួយមកតាំងខ្លួនជាអ្នកតំណាង នោះនាំឲ្យកិច្ចសន្យានោះមានវិការៈដែលអាចឈានទៅរកការមោឃៈបាន។

**ឧទាហរណ៍៖** លោក ក បានពុំបានទទួលនូវសិទ្ធិតំណាងណាមួយឡើយ ដោយបានអះអាងថាខ្លួនជាកូនរបស់លោក ខ ហើយបានប្រាប់ថា លោក ខ ដែលជាឪពុករបស់ខ្លួនបានប្រគល់សិទ្ធិតំណាងឲ្យខ្លួនក្នុងការផ្ទេរនូវលក់រថយន្តរបស់ឪពុកខ្លួនទៅឲ្យអ្នកដទៃ ទាំងឪពុករបស់លោក ក ផ្ទាល់មិនបានផ្ទេរសិទ្ធិណាមួយឲ្យទៅកាន់លោក ខ ឡើយ។ ដូច្នេះការតំណាងរបស់លោក ក ជាការតំណាងដោយគ្មានសិទ្ធិអ្វីទាល់តែសោះ។

## ២.២ បញ្ញត្តិជាមូលដ្ឋាននៃការមោឃភាពនៃអាពាហ៍ពិពាហ៍

ទោះបីជាមានការរៀបអាពាហ៍ពិពាហ៍រួចរាល់ នឹងត្រូវបានចុះលិខិតអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំ-សង្កាត់ ដែលចាត់ទុកថាត្រឹមត្រូវតាមលក្ខណៈច្បាប់ ដែលបានរៀបរាប់នៅខាងលើនេះ។ វាពិតជាត្រូវបានច្បាប់ទទួលស្គាល់ទៅតាមបទបញ្ញត្តិច្បាប់។ យ៉ាងណាមិញក៏នៅតែមានអាពាហ៍ពិពាហ៍មួយចំនួននៅមានវិការៈកើតឡើងជានិច្ចកាលក៏ព្រោះតែមានការលាក់បាំងនូវការពិតមួយចំនួន ឬដោយសារតែភាគីនៃអាពាហ៍ពិពាហ៍នោះពុំបានទទួលជ្រាបអំពីបញ្ហាច្បាប់ដែលជាប់ពាក់ព័ន្ធ។ ទើបបណ្ដាលឲ្យគាត់ត្រូវបានរៀបអាពាហ៍ពិពាហ៍ទាំងបង្ខំចិត្ត ចំណែកឯអាពាហ៍ពិពាហ៍មួយចំនួនមិនត្រឹមត្រូវទៅតាមច្បាប់ និងមានមូលហេតុផ្សេងៗទៀតដែលច្បាប់មិនទទួលស្គាល់។

មោឃភាពនៃអាពាហ៍ពិពាហ៍ វាគឺជាមធ្យោបាយមួយដែលនាំឲ្យចំណងនៃអាពាហ៍ពិពាហ៍មិនស្របច្បាប់មួយត្រូវបានបញ្ចប់ និងនាំឲ្យសហព័ន្ធនោះ និងញាតិរបស់សហព័ទ្ធនោះលែងជាញាតិរបស់សហព័ទ្ធម្ខាងទៀតផងដែរ។

[25] មាត្រា ៣៦៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

បើយោងទៅតាមខ្លឹមសារច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩មា ត្រាមួយចំនួនបានធ្វើការបញ្ញត្តិថាមូលហេតុដែលអាចចាត់ទុកថាអាពាហ៍ពិពាហ៍នោះ ត្រូវបានមោឃភាពគឺ ដោយសារតែមាននូវមូលហេតុជាច្រើនរួមមានដូចជា៖

- អាពាហ៍ពិពាហ៍ត្រូវបានធ្វើការមោឃៈ ប្រសិនបើអាពាហ៍ពិពាហ៍នោះ ចុះបញ្ជីនៅពេលដែលមានសហព័ទ្ធណាម្នាក់ឆ្កួត ឬមិនដឹងខុសត្រូវ។[26]
  បញ្ជាក់នៅត្រង់ចំណុចនេះប្រសិនបើសហព័ទ្ធនោះបានជាស្រួលបួលឡើងវិញហើយ ហេតុដែលនាំឱ្យចាត់ទុកជាមោឃៈនោះត្រូវបានរលាយទៅវិញដែរ។
- អាពាហ៍ពិពាហ៍ត្រូវទុកជាមោឃៈ កាលបើសហព័ទ្ធណាម្នាក់ប្តឹងថា ខ្លួនត្រូវបានគេចាប់បង្ខំឲ្យរៀបអាពាហ៍ពិពាហ៍។[27]
- អាពាហ៍ពិពាហ៍ត្រូវទុកជាមោឃៈ បើចំណងអាពាហ៍ពិពាហ៍មុនរបស់សហព័ទ្ធណាម្នាក់មិនទាន់បានរលាយដោយនៅមានចំណងអាពាហ៍ពិពាហ៍ចាស់នៅឡើយ។[28]
- អាពាហ៍ពិពាហ៍រវាងញាតិលោហិត ឬញាតិព័ន្ធក្នុងថ្នាក់ដែលច្បាប់ហាមឃាត់ ត្រូវចាត់ទុកជាមោឃៈ លើកលែងតែករណីដែលមានចែងក្នុងមាត្រា៨ វាក្យខ័ណ្ឌទី២នៃច្បាប់នេះ។[29]

ក្នុងករណីនេះដែរ ដើម្បីសិក្សាឱ្យកាន់តែមានភាពច្បាស់លាស់បន្ថែមបើយើងក្រឡេកមើលទៅលើច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារវិញ យើងឃើថាមោឃភាពនេះត្រូវបានធ្វើការបែងចែកជាពីរគឺ៖ មោឃភាពដាច់ខាត និងមោឃភាពមិនដាច់ខាត។

❖ <u>**មោឃភាពដាច់ខាត**</u>

**ការទាស់មុខស្មន់៖** សំដៅលើអាពាហ៍ពិពាហ៍រវាងញាតិលោហិត ឬញាតិពន្ធក្នុងថ្នាក់ដែលច្បាប់បានហាមឃាត់ត្រូវចាត់ទុកជា មោឃៈលើកលែងតែមានអញ្ញត្រកម្មក្នុងករណីពិសេសដែលមានចែងនៅក្នុងមាត្រា៨ វាក្យខ័ណ្ឌទី២ នៃច្បាប់ស្តីអាពាហ៍ពិពាហ៍ និងគ្រួសារ។

**ការមានភេទដូចគ្នា៖** អាពាហ៍ពិពាហ៍ទាំងឡាយណាដែលបានប្រព្រឹត្តឡើងមានភេទដូចគ្នា ត្រូវបានច្បាប់ចាត់ទុកថាមោឃភាពដាច់ខាត។

[26] មាត្រា ២១ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩
[27] មាត្រា ២៣ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩
[28] មាត្រា ២៤ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩
[29] មាត្រា ២៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩

❖ <u>មោឃភាពមិនដាច់ខាត</u>

**វិបល្លាសស្មារតី:** កាលណាមានសហព័ទ្ធណាមួយមានបញ្ហាវិកលចរឹក ឬមិនមានការដឹងខុសត្រូវនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ នាំឱ្យអាពាហ៍ពិពាហ៍នោះចាត់ទុកជាមោឃៈ។ ប៉ុន្តែប្រសិនបើសហព័ទ្ធនោះបានជាស្រួលបួលវិញហើយនោះ ហេតុដែលនាំឱ្យទុកជាមោឃៈនេះក៏ត្រូវលាយទៅវិញដែរ។

**មិនគ្រប់អាយុ:** អាពាហ៍ពិពាហ៍រវាងបុរសក្រោមអាយុ២០ឆ្នាំ ឬនារីក្រោមអាយុ១៨ឆ្នាំ ត្រូវចាត់ទុកជាមោឃភាព ប៉ុន្តែអាពាហ៍ពិពាហ៍នេះនឹងលែងមោឃៈវិញនៅពេលដែលប្តីប្រពន្ធនេះចម្រើនវ័យដល់អាយុតាមបញ្ញត្តិច្បាប់ ឬករណីដែលមានចែងក្នុងមាត្រា៥ វាក្យខ័ណ្ឌទី២ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ។

**ទ្វេពន្ធភាព:** បើចំណងអាពាហ៍ពិពាហ៍មុនរបស់សហព័ទ្ធណាម្នាក់មិនទាន់បានរលាយ ហើយសហព័ទ្ធនោះបានរៀបអាពាហ៍ពិពាហ៍ថ្មីទៀត វាជាហេតុនាំឲ្យអាពាហ៍ពិពាហ៍ថ្មីនោះ ត្រូវចាត់ទុកជាការមោឃលើកលែងតែករណីចែងក្នុងមាត្រា២៤ នៃវាក្យខណ្ឌទី២ នៃច្បាប់អាពាហ៏ពិពាហ៍ និង គ្រួសារ។

**ការបង្ខិតបង្ខំ:** កាលបើសហព័ន្ធណាម្នាក់ប្តឹងថា ខ្លួនត្រូវបានគេចាប់បង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ ជាហេតុនាំអាពាហ៍ពិពាហ៍នោះត្រូវបានមោឃភាព។ ចំពោះការប្តឹងសុំមោឃភាពនេះ ត្រូវផុតអាជ្ញាយុកាលប្រសិនបើការប្តឹងនោះមិនធ្វើក្នុងរយៈពេល ០៦ខែគិតចាប់ពីថ្ងៃដែលគេលែងបង្ខំនោះ។

ចំណែកឯនៅក្នុងអត្ថបទច្បាប់នៃក្រមរដ្ឋប្បវេណីបានធ្វើការបែងចែកជាពីរហេតុផលធំៗ ដែលយើងខ្ញុំនឹងលើកឡើងធ្វើការនៅខាងក្រោមនេះបន្ថែមទៀត។

### ២.២.១ មូលហេតុដោយគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍ គឺជាសេចក្តីស្រលាញ់កើតចេញពីមនោសចេតនា ដោយការព្រមព្រៀង ដោយស្ម័គ្រចិត្តនឹងគ្នាតាមរយៈគូភាគីទាំងពីររូប។ ប្រសិនណាជាផ្ទុយអំពីលក្ខណៈខាងលើនេះដោយហេតុអាពាហ៍ពិពាហ៍ត្រូវបានកើតឡើងដោយសារការបង្ខំ ការភ័ន្តច្រឡំលើមនុស្ស ឬដោយសារមានមូលហេតុផ្សេងទៀតដោយប្រការមិនសមគួរណាមួយ។

**ឧទាហរណ៍៖** អាពាហ៍ពិពាហ៍មួយបានប្រព្រឹត្តទៅដោយសារតែមានការបង្ខិតបង្ខំពីសំណាក់ឪពុកម្តាយ ឬពីសំណាក់ដៃគូរបស់សហព័ទ្ធម្ខាងទៀត ក្នុងគោលបំណងដោយដូរទៅនឹងអ្វីមួយជាដើម ដូច្នេះប្រព្រឹត្តឡើងនៅក្នុងសកម្មភាពបែបនេះត្រូវចាត់ទុកថាមោឃ។

**ឧទាហរណ៍៖** ចំណែករីឯអាពាហ៍ពិពាហ៍ខ្លះទៀត វាមិនមែនជាការបង្ខិតបង្ខំអ្វីទេ តែវាគឺជាការរៀបអាពាហ៍ពិពាហ៍ដោយមានការភ័ន្តច្រឡំទៅលើមនុស្ស ដែលការភ័ន្តច្រឡំនេះអាចទៅឋានៈរបស់បុគ្គល ឬចំពោះបុគ្គលដែលមានមុខមាត់ស្រដៀងគ្នាករណីកូនភ្លោះជាដើម។ លក្ខណៈនៃការភ័ន្តច្រឡំបែបនេះជាហេតុអាចនាំឲ្យអាពាហ៍ពិពាហ៍នោះត្រូវបានធ្វើការមោឃភាព។

### ២.២.៣ មូលហេតុមិនបានគោរពតាមនីតិវិធី

ការរៀបអាពាហ៍ពិពាហ៍ដែលគូភាគីពុំបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ឬមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍។ ប៉ុន្តែប្រសិនបើ គ្រាន់តែមានវិការៈតែបន្តិចបន្តួចលើនីតិវិធីប៉ុណ្ណោះទេ អានុភាពនៃអាពាហ៍ពិពាហ៍នេះមិនត្រូវបានធ្វើការរារាំងដោយសារហេតុនោះឡើយ។ ដូច្នេះនៅត្រង់ចំណុចនេះដោយយោងទៅតាមហេតុផលខាងលើ យើងអាចសន្និដ្ឋានបានថា ការមោឃភាពនៃអាពាហ៍ពិពាហ៍ដែលមិនបានគោរពទៅតាមនីតិវិធី វាមានសណ្ឋានដូចខាងក្រោម៖

- ភាគីមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍
- មិនមានការជូនដំណឹងជាសាធារណៈ (ករណីដែលពុំមានការបិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍)
- មិនមានការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍
- មិនមានការចុះបញ្ជីអាពាហ៍ពិពាហ៍

## ២.៣ នីតិវិធីនៃការមោឃភាពអាពាហ៍ពិពាហ៍

ក្រោយពីបានសិក្សាស្វែងយល់បាននូវសញ្ញាណ ក៏ដូចជាមូលហេតុនៃការមោឃភាពនៃអាពាហ៍ពិពាហ៍រួចមក យើងនឹងពាំនាំលោកអ្នកបានសិក្សា និងទទួលជ្រាបខ្លះៗ អំពីនីតិវិធីមួយចំនួនដែលមាននៅក្នុងផ្នែកនេះ។

### ២.៣.១ បុគ្គលដែលមានសិទ្ធិក្នុងការធ្វើមោឃភាព

ជាការពិតនៅពេលដែលលេចចេញនូវសញ្ញាណណាមួយដែលវាឈានទៅដល់ ការបង្ហាញពីតម្រុយមួយ ឬច្រើនចំណុចក្នុងការធ្វើមោឃភាពនៃអាពាហ៍ពិពាហ៍នេះ ហេតុនេះហើយទាមទារឲ្យយើងបានដឹងច្បាស់ថា តើមានភាគីណាខ្លះដែលមានអត្ថិភាពនៃសិទ្ធិក្នុងការដាក់ពាក្យប្តឹងអំពីបញ្ហានៃការមោឃភាពនេះ។ ក្នុងន័យនេះបុគ្គលណាក៏ដោយ ក៏មានសិទ្ធិក្នុងការមោឃភាពបានដែរឲ្យតែមានហេតុផលសមស្របដែរទទួលស្គាល់ដោយច្បាប់។ នៅត្រង់ចំណុចនេះ យើងអាចបរិយាយបានថា សហព័ទ្ធដែលជាដៃគូរស់នៅជាមួយគ្នាជាកត្តាដែលអាចដឹងអំពីបញ្ហានៃការមោឃភាពខ្លាំងជាងអ្នកណាទាំងអស់ យើងអាចនិយាយឲ្យខ្លីបានថា ជាជនរងគ្រោះផ្ទាល់នៃវិការៈអាពាហ៍ពិពាហ៍នេះ។

**ឧទាហរណ៍៖** លោក ក និង កញ្ញា ខ បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា តែការរៀបអាពាហ៍ពិពាហ៍នេះមិនមែនជាការប្រព្រឹត្តឡើងតាមរយៈការព្រមព្រៀងរវាងគ្នានឹងគ្នានោះទេ តែវាកើតឡើងដោយសារតែភាគីដែលជាដៃគូរសហព័ទ្ធម្ខាងទៀត ដែលជាលោក ក បាបង្ខិតបង្ខំនាងតែប៉ុណ្ណោះដោយសារតែឪពុកម្តាយរបស់កញ្ញា ខ បានជំពាក់លុយគ្រួសារលោក ក ច្រើនពេកគ្មានលទ្ធភាពក្នុងការសងត្រលប់ទៅវិញ។ អាស្រ័យហេតុនេះទើបបានជាកញ្ញា ខ យល់ព្រមទាំងបង្ខិតចិត្តរៀបការជាមួយលោក ក ទៅ។ កាលដែលមានស្ថានភាពជួបបែបនេះ កញ្ញា ខ អាចលើកយកមូលហេតុនៃការបង្ខិតបង្ខំនេះ ជាសំអាងក្នុងការមោឃភាពនៃអាពាហ៍ពិពាហ៍នោះ។

*បញ្ញាក់៖* ការសុំប្តឹងមោឃភាពនៃអាពាហ៍ពិពាហ៍ត្រូវផុតអាជ្ញាយុកាល ប្រសិនបើការប្តឹងនោះ មិនបានធ្វើឡើងក្នុងរយៈពេល ៦ខែ គិតពីថ្ងៃដែលគេលែងបង្ខំមក។[30]

ចំណែកឯភាគីដែលមានប្រយោជន៍នៅក្នុងការសុំមោភាពនៃអាពាហ៍ពិពាហ៍ ដោយខ្លួនសង្កេតឃើញ ឬមើលឃើញថាអាពាហ៍ពិពាហ៍ ដែលបានប្រព្រឹត្តទៅនេះវាមានវិការៈត្រង់ណាមួយដែលចង្អុលបង្ហាញទៅដល់ការសុំធ្វើមោភាពនៃអាពាពិពាហ៍នេះ ខ្លួនមានសិទ្ធិពេញលេញក្នុងការសុំប្តឹងបាន ដោយត្រូវលើកឡើងនូវមូលហេតុត្រឹមត្រូវ និងសមស្របទៅតាមវិធានច្បាប់ដែលបានកំណត់។ យើងដឹងហើយថា តំណាងស្ថាប័នអយ្យការ គឺជាតួអង្គដ៏សំខាន់ក្នុងការធានារក្សាការពារទៅដល់ផលប្រយោជន៍របស់សង្គម។ ក្នុងន័យនេះបានសេចក្តីថា នៅពេលដែលទទួលបាន ឬខ្លួនឯងផ្ទាល់បានដឹងឮនូវបញ្ហានៃវិការៈណាមួយនៃចំណងអាពាហ៍ពិពាហ៍ គឺតំណាងអយ្យការមានសិទ្ធិក្នុងការចាត់ការទៅតាមនីតិវិធីច្បាប់។ ម្យ៉ាងវិញទៀត មិនមែនទាល់តែភាគីដែលជាសាច់ញាតិនៃសហព័ទ្ធទាំងសងខាងនោះទេ សូម្បីតែភាគីផ្សេងៗដែលគិតថាខ្លួនមានផលប្រយោជន៍ក្នុងការហាមឃាត់នៃចំណងអាពាហ៍ពិពាហ៍នោះ ពួកគេក៏អាចសុំប្តឹងអំពីការមោឃភាពនៃអាពាហ៍ពិពាហ៍នោះបានផងដែរ។

### ២.៣.២ សមត្ថកិច្ចដោះស្រាយលើបណ្តឹងមោឃភាពអាពាហ៍ពិពាហ៍

ដោយផ្អែកទៅតាមស្មារតីនៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ នៅត្រង់ផ្នែកទី៣ ដែលបានបញ្ញត្តិអំពីមោឃភាពនៃអាពាហ៍ពិពាហ៍ បានចង្អុលបង្ហាញយ៉ាងច្បាស់ថា មានតែសហព័ទ្ធ រដ្ឋអាជ្ញា (ព្រះរាជអាជ្ញា) និង ជនដែលមានប្រយោជន៍ស្របច្បាប់ក្នុងការប្តឹងសុំមោឃភាពនៃចំណងអាពាហ៍ពិពាហ៍ទេ ទើបអាចដាក់ពាក្យប្តឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ទៅកាន់តុលាការប្រជាជនបាន។ ដូចនេះយើងអាចធ្វើការសន្និដ្ឋានបានថា មានតែតុលាការតែប៉ុណ្ណោះ ទើបមានសមត្ថកិច្ចក្នុងការសម្រេចសេចក្តីអំពីការមោឃភាពនៃអាពាហ៍ពិពាហ៍។

### ២.៣.៣ អានុភាពនៃការមោឃភាពអាពាហ៍ពិពាហ៍

កាលណាបើអាពាហ៍ពិពាហ៍មួយវាត្រូវបានមោឃភាព នោះវានឹងនាំឲ្យអាពាហ៍ពិពាហ៍នោះ មិនមានអានុភាពទាល់តែសោះ ចាប់តាំងពីពេលដែលបានបង្កើតអាពាហ៍ពិពាហ៍នោះមក។ ដូចនេះបណ្តឹងដែលបានធ្វើឡើងនៅឯតុលាការ គឺជាបណ្តឹងដែលទាមទារឲ្យបញ្ជាក់ពីមោឃភាពអាពាហ៍ពិពាហ៍តែប៉ុណ្ណោះ មិនមែនជាបណ្តឹងទាមទារមោឃភាពអាពាហ៍ពិពាហ៍នោះឡើយ។ ជាគោលការណ៍បណ្តឹងទាមទារឲ្យបញ្ជាក់ពីមោឃភាពនៃអាពាហ៍ពិពាហ៍ វាត្រូវបានធ្វើឡើងដោយអនុលោមទៅតាមនីតិវិធីដែលមានបញ្ញត្តិ នៅក្នុងច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។ ចំពោះបណ្តឹងដែលទាមទារឲ្យបញ្ជាក់ពីមោឃភាពអាពាហ៍ពិពាហ៍នេះ ត្រូវ

[30] មាត្រា ២៤ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩

បានសម្រេចឡើងដោយតុលាការតាមរយៈ ***សាលក្រម*** ។ ជាគោលការណ៍នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា សម្រាប់បណ្តឹងប្រភេទនេះមិនមានការកម្រិតពីបុគ្គលដែលអាចប្តឹងបាន និងអំឡុងពេលអាជ្ញាយុកាលណាមួយកំណត់ជាក់លាក់ឡើយ។

ហេតុដូច្នេះយើងអាចបកស្រាយបានថា គ្រប់ជនដែលមានប្រយោជន៍សុទ្ធតែអាចប្តឹងបានទាំងអស់ដោយពុំមានកម្រិតអំឡុងពេលនៃអាជ្ញាយុកាលនោះឡើយ។

# ជំពូកទី៣
# ការលុបចោលនៃអាពាហ៍ពិពាហ៍

មនុស្សប្រុស-ស្រី នៅពេលដល់វ័យដែលច្បាប់បានកំណត់ថាអាចរៀបអាពាហ៍ពិពាហ៍បាន នោះពួកគេមានសិទ្ធិគ្រប់គ្រាន់ក្នុងការរៀបអាពាហ៍ពិពាហ៍ តាមអ្វីដែលជាការរៀបចំរបស់អាណាព្យាបាលរបស់ពួកគេ និងការព្រមព្រៀងពីសាមីភាគីផងដែរ។ ដើម្បីរៀបអាពាហ៍ពិពាហ៍ ដែលអាចចាត់ទុកថាត្រឹមត្រូវតាមច្បាប់គឺត្រូវគោរពនូវលក្ខខណ្ឌមួយចំនួនដូចជា លក្ខខណ្ឌគ្រឹះ នឹង លក្ខខណ្ឌទម្រង់។ យ៉ាងណាមិញប្រសិនបើ អាពាហ៍ពិពាហ៍មិនគោរពទៅតាមលក្ខខណ្ឌនៃច្បាប់នោះអាចនឹងមានទណ្ឌកម្ម ហើយទណ្ឌកម្មទាំងនោះត្រូវទទួលនៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ និងក្នុងពេលរៀបអាពាហ៍ពិពាហ៍។

មុនពេលរៀបអាពាហ៍ពិពាហ៍ ឪពុកម្តាយ ឬបុគ្គលគ្រប់រូបដែលមានប្រយោជន៍ក្នុងនោះអាចធ្វើបណ្តឹងប្តឹងទាស់ទៅកាន់មន្ត្រីអាត្រានុកូលដ្ឋាន ដើម្បីឲ្យមន្ត្រីមានសមត្ថកិច្ចបញ្ឈប់អាពាហ៍ពិពាហ៍នោះ និងរងចាំរហូតដល់បណ្តឹងទាស់នោះ ត្រូវបានដោះស្រាយចប់។ ប្រសិនបើតុលាការបដិសេធបណ្តឹងទាស់នោះចោល អនាគតប្តីប្រពន្ធអាចរៀបអាពាហ៍ពិពាហ៍បាន។ ប៉ុន្តែប្រសិនណាបើតុលាការយល់ថា អាពាហ៍ពិពាហ៍នោះមិនត្រឹមត្រូវមន្ត្រីអត្រានុកូលដ្ឋានត្រូវបញ្ឈប់អាពាហ៍ពិពាហ៍នោះ។ ទណ្ឌកម្មដែលតែងតែកើតមានឡើង ក្រោយការរៀបអាពាហ៍ពិពាហ៍ គឺកើតឡើងដោយការមិនបានគោរព និងបំពេញទៅតាមលក្ខខណ្ឌដែលច្បាប់បានកំណត់នោះនឹងនាំឲ្យបុគ្គលដែលមានផលប្រយោជន៍មួយចំនួនអាចធ្វើការប្តឹងទាមទារលុបចោលបាន។

ផ្អែកទៅតាមខ្លឹមសារខាងលើទាំងអម្បាលមាន ជាលក្ខខណ្ឌចាំបាច់ក្នុងការរៀបអាពាហ៍ពិពាហ៍ ហើយត្រឹមត្រូវទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដែលបានកំណត់យ៉ាងច្បាស់លាស់ក្នុងការអនុវត្ត។ បើមិនអនុវត្ត និងមិនគោរពគោលការណ៍នៃច្បាប់នោះទេ អាពាហ៍ពិពាហ៍ដែលមិនគោរពនោះ នឹងត្រូវចាត់ទុកថា ជាអាពាហ៍ពិពាហ៍ផ្ទុយនឹងច្បាប់កំណត់។ ជាហេតុដែលនាំឲ្យអាពាហ៍ពិពាហ៍នោះ អាចត្រូវលុបចោលបាន។ អាពាហ៍ពិពាហ៍ដែលអាចលុបចោលបាន គឺជាការរំលាយអាពាហ៍ពិពាហ៍ដែលបានកើតឡើង ហើយនឹងមានអនុភាពរួចហើយ។

## ៣.១ មូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍

អាពាហហ៍ពិពាហ៍មួយដែលបានអនុវត្តទៅតាមវិធានច្បាប់បានត្រឹមត្រូវ វាមិនអាចត្រូវបានធ្វើការលុបចោលទៅតាមទំនើងចិត្តឡើយ លុះត្រាតែមានវិការៈណាមួយបានមានឡើងជាក់ជាមិនខាន។ ការលុបចោលអាពាហ៍ពិពាហ៍ គឺជាការប្រកាសទណ្ឌកម្មដែលលុបបំបាត់អានុភាពនៃអាពាហ៍ពិពាហ៍នោះ ដោយសារតែមានការបំពានអំពីបញ្ញត្តិច្បាប់ណាមួយបានកើតមានឡើង។

### ៣.១.១ មូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ

#### ៣.១.១.១ មិនគ្រប់អាយុរៀបអាពាហ៍ពិពាហ៍

ចំពោះប្រទេសកម្ពុជានៅពេលបច្ចុប្បន្នបានកំណត់អាយុ១៨ឆ្នាំ ដែលជាអាយុនីតិភាពសមរម្យ នឹងត្រូវរៀបអាពាហ៍ពិពាហ៍បាន។[31] ការកំណត់អាយុបែបនេះគ្រប់បុគ្គលដែលរៀបអាពាហ៍ពិពាហ៍ គឺត្រូវបានកំណត់យ៉ាងច្បាស់លាស់ ដែលមិនអាចឲ្យបុគ្គលណាបំពាន ទៅលើលក្ខខណ្ឌមួយនេះបានឡើយ។ លើកលែងតែករណីពិសេសមួយចំនួនតែប៉ុណ្ណោះ។ ការកំណត់អាយុបុគ្គលដែលត្រូវរៀបអាពាហ៍ពិពាហ៍ គឺត្រូវឲ្យពួកគេគោរពនូវភាពជាទំនួលខុសត្រូវចំពោះគ្រួសារ ហើយគ្រប់គ្រាន់នូវលក្ខណៈសម្បត្តិមានទាំងកាយសម្បទាពេញលេញ ទាំងផ្នែកបញ្ញាស្មារតីរឹងមាំមានមុខរបរចិញ្ចឹមជីវិតច្បាស់លាស់ ជាពិសេសមានទំនួលខុសត្រូវគ្រប់គ្រាន់សម្រាប់មើលថែរក្សាកូនៗ ដែលជាបុត្រា បុត្រី របស់ពួកគេ បន្ទាប់ពីពួកគេបានរៀបអាពាហ៍ពិពាហ៍រួចហើយ។ មួយវិញទៀតនោះបើសិនជាពួកគេមិនទាន់ទទួលបាននូវអត្តាធីនភាពតាមច្បាប់ ពួកគេក៏មិនអាចរៀបអាពាហ៍ពិពាហ៍បានដែរ។

#### ៣.១.១.២ អាពាហ៍ពិពាហ៍រវាងញ្ញាតិលោហិត

ចំពោះភាគីទាំងពីរដែលមាន បុរស និងនារី ជាភាគីនៃអាពាហ៍ពិពាហ៍ហើយបានដល់នីតិភាពក្តី ក៏មិនអាចរៀបអាពាហ៍ពិពាហ៍បានដែរ បើភាគីទាំងសងខាងជាញ្ញាតិលោហិតខ្សែផ្ទាល់ ឬ សាខាញ្ញាតិលោហិតក្នុង៣ថ្នាក់រាប់ទាំងថ្នាក់ទី៣ផង។[32] ការរៀបអាពាហ៍ពិពាហ៍ជាមួយញាតិដែលមានសាខាជិតបែបនេះ ច្បាប់ត្រូវបានហាមឃាត់ជាដាច់ខាត ហើយការរៀបអាពាហ៍ពិពាហ៍បែបនេះ ជាមូលហេតុទាក់ទងនឹងសីលធម៌សង្គមផងដែរ។ ការរៀបអាពាហ៍ពិពាហ៍ដែលមានសាខាញាតិជិតគ្នា នៅពេលដែលមានកូន កូនដែលកើតមកគេអាចប្រឈមនឹងមានជម្ងឺផ្សេងៗ ឬ អាចជាខ្សោយពីកំណើត កាយសម្បទាមិនល្អ ជាពិសេសគឺអាចនឹងមានការពិការទៀត ក៏មានដែរ។ ដោយឡែកបើនិយាយពីសង្គមវិញ គឺផ្ទុយទៅនឹងសីលធម៌សង្គមបាត់ទៅហើយ ហើយអាចប៉ះពាល់ខ្លាំងទៀតផង ហើយសង្គមក៏មិនទទួលស្គាល់នៅអាពាហ៍ពិពាហ៍មួយនោះដែរ។ បើយើងគិតពីការបញ្ជាប់នៅញាតិភាពរវាងឪពុកចិញ្ចឹម ចំពោះកូនស្មុំពេញលេញ ឬកូនស្មុំធម្មតា ក៏ច្បាប់ហាមមិនអោយរៀបអាពាហ៍ពិពាហ៍បានឡើយ។ ទោះបីមានការកាត់ផ្តាច់នូវទំនាក់ទំនងរវាងកូនស្មុំ ឪពុកម្តាយបង្កើតកូនស្មុំពេញលេញក៏ដោយ ក៏ទំនាក់ទំនងខ្សែលោហិតតាមធម្មជាតិ មិនត្រូវបានកាត់ផ្តាច់។ ហេតុដូច្នេះហើយ ទើបការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ខ្សែលោហិតជិតគ្នា នៅតែត្រូវបានហាមឃាត់ចំពោះញាតិលោហិតខ្សែផ្ទាល់។

---

[31] មាត្រា ៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩

[32] មាត្រា ៩៥១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ៣.១.១.៣ អាពាហ៍ពិពាហ៍ចំពោះញាតិពន្ធ

ការរៀបអាពាហ៍ពិពាហ៍ គឺមិនអាចប្រព្រឹត្តទៅបានឡើយចំពោះញាតិពន្ធសាខាញាតិផ្ទាល់ នឹងសាខាញាតិថ្នាក់ទី៣ និងរាប់ទាំងថ្នាក់ទី៣ផងដែរ។ ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធខ្សែផ្ទាល់ នឹងញាតិដែលធ្លាប់ញាតិពន្ធកាលពីមុន។ ដោយសារទំនាក់ទំនងទាំងនេះ វាប្រហាក់ប្រហែលនឹងមានលក្ខណៈស្រដៀងគ្នាទៅ នឹងញាតិខ្សែលោហិតផ្ទាល់របស់ភាគីដែរនឹងទំនាក់ទំនងឪពុកម្ដាយ កូនអាពាហ៍ពិពាហ៍បែបនេះក៏មិនមែនជាការគួរ ឬ ជាការសមរម្យទេ។ ចំពោះអាពាហ៍ពិពាហ៍ខាងលើ គឺច្បាប់មិនអនុញ្ញាតិឲ្យធ្វើការរៀបចំបានទេ។ ដោយសារទំនាក់ទំនង រវាងញាតិពន្ធ នឹងញាតិពន្ធថ្នាក់ទី៣រួមទាំងញាតិថ្នាក់ទី៣ផងនោះ គឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធស្រដៀងទៅនឹងញាតិលោហិតខ្សែផ្ទាល់ នឹងសាខាញាតិលោហិតផ្ទាល់ផងដែរ។ ប៉ុន្តែនៅក្នុងករណីមួយចំនួននៅក្នុងប្រទេសកម្ពុជាយើង នៅពេលដែលភាគីម្ខាងនៃសហព័ទ្ធបានទទួលមរណៈភាព ហើយសហព័ទ្ធម្ខាងទៀតបានរៀបការជាមួយ ប្អូន ឬ បងថ្លៃរបស់សហព័ទ្ធជាដើម។ ដោយសារក្នុងគោលបំណងជួយមើថែរក្សា កូនៗដែលនៅក្នុងបន្ទុក ឬ កូនដែលជាកូនរបស់ភាគីដែលទទួលមរណៈភាព។

### ៣.១.១.៤ អាពាហ៍ពិពាហ៍អំឡុងពេលហាមឃាត់

នៅក្រោយពេលអាពាហ៍ពិពាហ៍ចាស់ដែលត្រូវបានរំលាយ ដោយយោងតាមមាត្រា ៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ នឹងគ្រួសារ ឆ្នាំ១៩៨៩។ នារីអាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន ក៏ប៉ុន្តែត្រូវស្ថិតនៅក្នុងភាពជាពោះម៉ាយរយៈពេល៣០០ថ្ងៃ។ គិតចាប់ពីពេលដែលអាពាហ៍ពិពាហ៍ចាស់ត្រូវបានរំលាយ ដោយមូលហេតុប្តីស្លាប់ ឬចាប់ពីការប្រកាសសាលក្រម ដែលសម្រេចអំពីមោឃភាពនៃអាពាហ៍ពិពាហ៍ ឬចាប់ពីថ្ងៃដែលសាលក្រមស្ថាពរនៃការលែងលះគ្នា។ ក៏ប៉ុន្តែនៅក្នុងក្រមរដ្ឋប្បវេណីបច្ចុប្បន្នបានកែប្រែរយៈពេលនៃការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍ថ្មីត្រឹមតែ ១២០ថ្ងៃតែប៉ុណ្ណោះ បន្ទាប់ពីថ្ងៃរំលាយ ឬការលុបចោលនៃអាពាហ៍ពិពាហ៍មុន។ ចំពោះស្ត្រីដែលបានលែងលះជាមួយស្វាមី អាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន ក្នុងរយៈពេល១២០ ថ្ងៃត្រូវបានកន្លងផុត។ អាពាហ៍ពិពាហ៍ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ក្នុងរយៈពេលនេះ គឺត្រូវបានលុបចោល។ អំឡុងពេលនៃការហាមឃាត់នេះ ជាអំឡុងពេលដែលសមស្របមួយដែលច្បាប់ទុករយៈពេលចំពោះស្ត្រី ដើម្បីជៀសវាងការជួបបញ្ហាក្នុងកំណត់ពេលមានបុត្តភាព។

### ៣.១.១.៥ ទ្វេពន្ធភាព

បុរសដែលមានសហព័ទ្ធហើយ ពុំអាចរៀបអាពាហ៍ពិពាហ៍ទៀតបានឡើយ។[33] ហើយត្រូវមានពិរុទ្ធក្នុងបទទ្វេពន្ធភាព ប្រសិនបើបុរស ឬ នារីណាដែលមានចំណងអាពាហ៍ពិពាហ៍មុនមិនទាន់រលាយនៅឡើយ ហើយ

[33] មាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

ទៅចុះបញ្ជីអាពាហ៍ពិពាហ៍ថ្មីមួយទៀត។[34]ការសម្រេចយករបបឯកពន្ធភាពបុរសនារី ត្រូវបានហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍លើសពីម្នាក់បានឡើយ។ អាពាហ៍ពិពាហ៍ត្រូវតែធ្វើតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ នឹងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយ ប្រពន្ធមួយ។[35] ចំណែកនារីវិញក៏ដូចគ្នាដែរ ជាគោលការណ៍នេះត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ រីឯក្រមរដ្ឋប្បវេណីក៏បានហាមឃាត់ ចំពោះបុគ្គលទាំងឡាយណាដែលមានចំណងអាពាហ៍ពិពាហ៍មុនមិនទាន់រលាយ ហើយមកចុះបញ្ជី ឬ ដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ថ្មីនោះ ពុំអាចរៀបអាពាហ៍ពិពាហ៍បានទេ។

#### ៣.១.១.៦ អាពាហ៍ពិពាហ៍ដោយការឆបោក ឬដោយការគំរាម

អាពាហ៍ពិពាហ៍ដែលមានវិការៈក្នុងការបង្ហាញឆន្ទៈដោយការឆបោកឬ ការគំរាម អាចទាមទារទៅតុលាការឱ្យលុបចោលអាពាហ៍ពិពាហ៍នោះបាន។[36] ការឆបោក ឬការគំរាមគឺសម្តៅទៅលើការធ្វើឲ្យភាគីម្ខាងទៀតយល់ព្រមរៀបអាពាហ៍ពិពាហ៍ ដោយសារមធ្យោបាយខុសច្បាប់នឹងការបោកប្រាស់បុគ្គលនោះឲ្យធ្លាក់ចូលក្នុងការ ភ័ណ្ឌច្រឡំ ឬធ្វើឲ្យបុគ្គលនោះធ្វើតាមដោយការជូនដំណឹង អំពីភាពមិនល្អទៅភាគីម្ខាងទៀត។ ការឆបោក ឬ ការគំរាមកំហែង គឺមានភាពចាំបាច់ត្រូវតែមានការផ្ទុយពីច្បាប់ នឹងមានកម្រិតខ្ពស់ ការឆបោក ឬគំរាមមានលក្ខណៈ បោកប្រាស់ បោកបញ្ឆោតនៅក្នុងរូបភាពណាមួយដោយពាក្យសម្តី ឬ អំពើគំរាមកំហែង ក្នុងរូបភាពផ្សេងទៀតដែលមានលក្ខណៈជាការបង្ខិតបង្ខំផ្នែកផ្លូវភេទជាដើម។

### ៣.១.២ មូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

ជាគោលការណ៍ការរៀបអាពាហ៍ពិពាហ៍រវាងជនជាតិជនខ្មែរ នឹងជនជាតិបរទេសត្រូវផ្អែកលើការស្ម័គ្រចិត្ត នឹងឆន្ទៈផ្ទាល់របស់សាមីខ្លួន និងត្រូវអនុវត្តទៅតាមលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ នឹងលិខិតបទដ្ឋាននានាហើយមានចែងនៅក្នុងប្រទេសកម្ពុជា។ អាពាហ៍ពិពាហ៍ត្រូវបានហាមឃាត់ជាដាច់ខាតចំពោះការបង្កើតតាមរយៈ ឈ្មួញកណ្តាល ភ្នាក់ងាររើសគូស្រករ ឬក្រុមហ៊ុនធ្វើអាជីវកម្ម អាពាហ៍ពិពាហ៍បោកបញ្ឆោត។ នៅក្នុងគោលបំណងកេញប្រវ័ញ្ចកម្លាំងពលកម្ម ការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ។ ហេតុដូចនេះប្រសិនបើភាគីរៀបអាពាហ៍ពិពាហ៍បានរំលោភបំពាន ទៅលើលក្ខខណ្ឌដែលមានខាងលើនេះ អាពាហ៍ពិពាហ៍ដែលកើតឡើងហើយនោះនឹងត្រូវបានលុបចោលដោយផ្អែកទៅលើមូលហេតុដូចខាងក្រោមនេះ៖

---

[34] មាត្រា ៤ នៃច្បាប់ស្តីពី ឯកពន្ធភាព ឆ្នាំ២០០៦

[35] មាត្រា ២ នៃច្បាប់ស្តីពី ឯកពន្ធភាព ឆ្នាំ២០០៦

[36] មាត្រា ៩៦៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ៣.១.២.១ អាពាហ៍ពិពាហ៍ដោយគ្មានឆន្ទៈ ឬ ដោយការបង្ខិតបង្ខំ

អាពាហ៍ពិពាហ៍ ដែលត្រូវបានធ្វើឡើងដោយភាគីនៃអាពាហ៍ពិពាហ៍ ហើយគ្មានឆន្ទៈពិតប្រាកដក្នុងការរៀបអាពាហ៍ពិពាហ៍នោះទេវាជាអាពាហ៍ពិពាហ៍ដែលគ្មានឆន្ទៈ។ ការបង្ហាញឆន្ទៈរបស់ឪពុកម្តាយវាមិនមែនជាលក្ខខណ្ឌគតិយុត្តឡើយក្នុងការរៀបអាពាហ៍ពិពាហ៍ទេ។ ផ្ទុយទៅវិញ អាពាហ៍ពិពាហ៍ដែលកើតឡើងដោយការបង្ហាញឆន្ទៈរបស់ឪពុកម្តាយវិញនោះ វាជាអាពាហ៍ពិពាហ៍មិនបានកើតឡើងក្នុងឆន្ទៈពិតប្រាកដរបស់គូរភាគីនៃអាពាហ៍ពិពាហ៍ទេ។ ម៉្យាងវិញទៀតអាពាហ៍ពិពាហ៍ដែលស្របច្បាប់ជាដាច់ខាត គឺត្រូវតែធ្វើឡើងដោយគ្មានការបង្ខិតបង្ខំការបន្លំឆបោកការគំរាមគំហែង ការបោកប្រាស់ អំពីសំណាក់ភាគីម្ខាងទៀតនៃអាពាហ៍ពិពាហ៍ ឬបុគ្គលដែលជាតតិយជនឡើយ។ អាពាហ៍ពិពាហ៍នោះ កើតឡើងដោយឆន្ទៈរវាងភាគីខ្មែរ និងភាគីជនបរទេសយ៉ាងណាមិញ ភាគីត្រូវទៅបង្ហាញឆន្ទៈនៅមុខមន្រ្តីអាត្រានុកូលដ្ឋានឃុំ-សង្កាត់ខាងលំនៅដ្ឋានដែលជាជនជាតិខ្មែរ។ ដោយការបង្ហាញឆន្ទៈនោះ ភាគីទាំងសងខាង ត្រូវស្ថិតនៅក្នុងសភាព ដឹងខុស ដឹងត្រូវ មិនស្ថិតនៅក្នុងស្ថានភាពស្រវឹង ឬ ក្នុងស្ថានភាពវង្វេងស្មារតី ឬ ស្ថិតនៅក្នុងស្ថានភាពមួយដែលមានលក្ខណៈដូចត្រូវថ្នាំសណ្តំជាដើម ។

### ៣.១.២.២ អាពាហ៍ពិពាហ៍ដោយភ្នាក់ងាររើសគូរស្រករ

ករណីមួយចំនួនធំដែលកើតមានឡើង នៅក្នុងប្រទេសកម្ពុជាយើងនាពេលសព្វថ្ងៃនេះ អាចថាជា ការរួមគំនិតមួយដែលទាក់ទង នឹងការរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ រវាងជនជាតិខ្មែរ នឹងជនជាតិបរទេស។ ហើយពួកគេបានបង្កើតទំនាក់ទំនងមួយលួចរៀបអាពាហ៍ពិពាហ៍មួយគ្នានៅកម្ពុជា។ ហើយគោលបំណងនៅពេលដែលពួកគេបានទៅដល់គោលដៅ ឬប្រទេសដែលជាទីកន្លែងដែលពួកគេចង់ទៅ ទើបគេចាប់ផ្តើមលែងលះគ្នា ការធ្វើទង្វើបែបនេះ គឺដើម្បីឲ្យខ្លួនបានទៅរស់នៅបរទេស ដើម្បីធ្វើការ ឬអាចទៅរស់នៅទីនោះដោយស្របច្បាប់។ ក្នុងគោលបំណងដើម្បីទទួលបានសញ្ជាតិពីបណ្តាលប្រទេសទាំងនោះ។ ជាក់ស្តែងប្រទេសទាំងនោះ មានដូចជាប្រទេសអូស្រ្តាលី សហរដ្ឋអាមេរិច ប្រទេសបារាំង ប្រទេសកាណាដា ប្រទេសកូរ៉េ នឹង ប្រទេសដទៃផ្សេងទៀត។ នៅពេលដែលទទួលបានសញ្ជាតិរួចហើយគេនឹង ធ្វើការធានាសាច់ញាតិរបស់ពួកគេទៅអាចមានឪពុកម្តាយបងប្អូន ជាដើម ដើម្បីទៅរស់នៅជាមួយ។ ច្បាប់នៃព្រះរាជាណាចក្រកម្ពុជាមិនអនុញ្ញាតដាច់ខាត ចំពោះអាពាហ៍ពិពាហ៍ ដែលធ្វើឡើងតាមរយៈភ្នាក់ងាររើសគូស្រករ ឈ្មួញកណ្តាល ឬក្រុមហ៊ុនអាជីវកម្ម[37]។

### ៣.១.២.៣ អាពាហ៍ពិពាហ៍ដោយការឆបោក

ដោយសារជីវភាពក្រីក្រទាល់លំបាក បូករួមជាមួយនឹងភារកិច្ច ត្រូវថែរក្សាកូនៗ ផ្គត់ផ្គង់ដល់ក្រុមគ្រួសារស្រ្តីមួយចំនួននៅកម្ពុជាបានលង់នឹងការឆបោក កលល្បិចរបស់ជនបរទេសមួយចំនួន ដែលពួកគេបានសន្យាថា

---

[37] មាត្រា ៣ នៃអនុក្រឹត្យស្តីពី ការកំណត់បែបបទ និងនីតិវិធីរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ឆ្នាំ២០០៨

នឹងរៀបអាពាហ៍ពិពាហ៍ពិតប្រាកដ។ ដើម្បីយកទៅនៅបរទេសជាមួយ ដោយត្រឹមត្រូវតាមច្បាប់ នៅក្នុងគោលបំណងដែលពួកគេយល់ព្រមរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស គឺទទួលបានប្រាក់ ហើយអាចផ្ញើមកស្រុកដើម្បីយកមកជួយដល់ក្រុមគ្រួសារ និងជីវភាពរស់នៅជាប្រចាំ។ ទើបស្ត្រីទាំងនោះ ធ្វើការសម្រេចចិត្តរៀបអាពាហ៍ ពិពាហ៍ជាមួយជនបរទេស។ ទើបបណ្តាលឲ្យស្ត្រីទាំងនោះ ចាញ់បោកជនបរទេស ដោយការប្រើល្បិច ការបោកបញ្ឆោត ហើយយកពួកគេទៅជួញដូរ ធ្វើជាអ្នកបម្រើក្នុងផ្ទះ ជាទាសករក៏មានដែរ។ ម៉្យាងទៀតអាចធ្វើអាជីកម្មផ្លូវភេទទៀតផង។ល។ ទង្វើដែលធ្វើទាំងនេះគឺជាទង្វើខុសច្បាប់ និងអសីលធម៌បំផុត កត្តាទាំងនេះបានជះឥទ្ធិពលយ៉ាងខ្លាំងចំពោះចំពោះសង្គមកម្ពុជា។ ទើបធ្វើឲ្យរាជរដ្ឋាភិបាលសម្រេចចបង្កើតនៅច្បាប់ស្តីពីការហាមឃាត់ចំពោះអាពាហ៍ពិពាហ៍ដែលមានភាពក្លែងក្លាយ បោកបញ្ឆោត ក្នុងគោលបំណង គេញប្រវញ្ចកម្លាំងពលកម្ម ការជួញដូរមនុស្ស ឬ ធ្វើអាជីវកម្មផ្លូវភេទ។

## ៣.២ នីតិវិធីនៃការលុចចោល

ជាទូទៅនៅក្នុងទំនាក់ទំនងគតិយុត្ត ករណីដែលជាមូលហេតុនៃការលុបចោលនោះ អ្នកដែលមានសិទ្ធិត្រូវអនុវត្តក្នុងអំឡុងពេលនៃអាជ្ញាយុកាលមិនឲ្យផុតកំណត់។ ប៉ុន្តែបើក្នុងករណី ការប្តឹងលុបចោលអាពាហ៍ពិពាហ៍ ជាគោលការណ៍មិនមានរយៈពេលកំណត់ទេ នោះអ្នកដែលមានសិទ្ធិក្នុងការដាក់ពាក្យប្តឹងអាចដាក់ពាក្យបណ្តឹងបានគ្រប់ពេល។ នៅពេលដែលខ្លួនបានដឹងអំពីការរៀបអាពាហ៍ពិពាហ៍ ដែលមានលក្ខណៈមិនស្របច្បាប់របស់ខ្លួន ហើយភាគីមានបំណងចង់លុបចោលនូវ អាពាហ៍ពិពាហ៍ដែលខុសច្បាប់នោះ។ លើកលែងតែការប្តឹងលុបចោលអាពាហ៍ពិពាហ៍ ដោយមូលហេតុអាយុ អំឡុងពេលហាមឃាត់ស្ត្រីនឹងការឆបោក ឬ ការគំរាមប៉ុណ្ណោះ។ ទើបមានការកំណត់អំពីអំឡុងពេលច្បាស់លាស់នៅក្នុងការប្តឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍នោះ។

### ៣.២.១ អាជ្ញាយុកាលនៃការប្តឹងលុបចោល

#### ៣.២.១.១ អាជ្ញាយុកាលដែលកំណត់ដោយច្បាប់

នៅពេលជនដែលមិនគ្រប់អាយុរៀបអាពាហ៍ពិពាហ៍ លុះដល់អាយុអាចរៀបអាពាហ៍ពិពាហ៍ សិទ្ធិដែលអាចទាមទារឲ្យលុបចោលក៏ត្រូវបានរលត់ដោយមូលហេតុនេះដែរ។ ចំពោះការបំពានលើលក្ខខណ្ឌក្នុងការរៀបអាពាហ៍ពិពាហ៍ប៉ុន្តែវាត្រូវបានជួសជុលរួចហើយ ដូចនេះវាលែងប្រឆាំងទៅនឹងសង្គមទៀតហើយ។ ទោះបីជាជនក្រៅពីភាគីអនុវត្តសិទ្ធិលុបចោលក៏ដោយ ក៏ភាគីនៃអាពាហ៍ពិពាហ៍នោះ នៅតែអាចរៀបអាពាហ៍ពិពាហ៍បានម្តងទៀតបានដែរ។ ជនដែលបានរៀបអាពាហ៍ពិពាហ៍ មិនអាចយកមូលហេតុអាយុដើម្បីប្តឹងលុបចោលអាពាហ៍ពិពាហ៍ទ កាលណាអនីតិជននោះបានគ្រប់អាយុរៀបអាពាហ៍ពិពាហ៍ហើយ។ ទោះបីជាយ៉ាងណាក្តីជនដែលមិនគ្រប់អាយុរៀបអាពាហ៍ពិពាហ៍មានសិទ្ធិលុបចោលអាពាហ៍ពិពាហ៍នឹងធ្វើសច្ចានុមតិ ក្នុងអំឡុងពេលបីខែ បន្ទាប់

នោះគឺជននោះបានដល់អាយុរៀបអាពាហ៍ពិពាហ៍។ សម្រាប់ការលុបចោលអាពាហ៍ពិពាហ៍ ដោយមូលហេតុអាយុនេះ គឺវាជាផលប្រយោជន៍ឯកជន។ ដូច្នេះហើយសិទ្ធិលុបចោល ត្រូវបានរលត់បន្ទាប់ពីសាមីជនបានផ្ដល់សច្ចានុមតិ ក្នុងអំឡុងពេលបីខែ។

**៣.២.១.២ អវិជ្ជាយុកាលដែលកើតឡើងដោយការបន្ធាញឆន្ទះ**

**ក. អំឡុងពេលហាមឃាត**

បញ្ញត្តិស្ដីអំពីអំឡុងពេលនៃការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបាន គឺពុំអាចទាមទារឲ្យលុបចោលនូវអាពាហ៍ពិពាហ៍នោះបានឡើយ ប្រសិនបើរយៈពេល ១២០ថ្ងៃ ត្រូវបានកន្លងផុតទៅ។[38] បញ្ញត្តិនេះមានក្នុង (មាត្រា ៩៥០) នៃក្រមរដ្ឋប្បវេណី។ ទោះបីជាមានបញ្ញត្តិនៃច្បាប់បានទុករយៈពេលសម្រាប់ការលុបចោលពិតមែន ក៏ប៉ុន្តែសិទ្ធិលុបចោលនឹងត្រូវរលត់នៅរយៈពេល១២០ថ្ងៃ នៅពេលដែលរកឃើញថានារីម្នាក់នោះគ្មានផ្ទៃពោះ។ ហើយសិទ្ធលុបចោលនោះក៏ត្រូវបានរលត់ផងដែរ ម៉្យាងវិញទៀតក្នុងករណីដែលនារីនោះមានផ្ទៃពោះក្រោយការរៀបអាពាហ៍ពិពាហ៍ថ្មី។

**ខ. មូលហេតុដោយការឆបោក ឬការគំរាម**

ការឆបោក ឬការគំរាម វាជាមូលហេតុនៃការលុចោលអាពាហ៍ពិពាហ៍ដែលមានលក្ខខណ្ឌជាផលប្រយោជន៍ឯកជន។ ដូចនេះសិទ្ធិលុបចោលនឹងត្រូវបានរលត់នៅពេលដែលភាគីបានធ្វើសច្ចានុមតិ ក្នុងអំឡុងពេលបីខែ គិតចាប់ពីអំឡុងពេលដែលភាគីបានឃើញអំពីការឆបោកឬរួចខ្លួនពីការគំរាមបានកន្លងទៅផុត។

**៣.២.២ ភាគីដែលមានសិទ្ធិប្ដឹងលុបចោលអាពាហ៍ពិពាហ៍**

ករណីការលុបចោលអាពាហ៍ពិពាហ៍មានលក្ខខណ្ឌខុសគ្នាទៅនឹង មោឃភាពមិនបាត់បង់អានុភាពដោយស្វ័យប្រវត្តិនោះទេ។ យ៉ាងណាមិញយើងដឹងហើយថាការលុបចោលអាពាហ៍ពិពាហ៍នេះវាពិតជាមានសារៈសំខាន់ណាស់សម្រាប់ជាប្រយោជន៍ដល់ភាគីដែលទទួលរងគ្រោះ ដោយសារការរៀបអាពាហ៍ពិពាហ៍នោះ។ ដូចនេះហើយច្បាប់បានតម្រូវឲ្យគ្រប់ជនណាដែលមានផលប្រយោជន៍ក្នុងរឿងនេះ មានសិទ្ធិក្នុងការប្ដឹងទៅកាន់តុលាការ ដើម្បីស្នើឲ្យតុលាការសម្រេចសេចក្ដី។ ក្នុងនោះដែរយើងឃើញថាមានភាគីដែលមានសិទ្ធិក្នុងការក្នុងប្ដឹងលុបចោលអាពាហ៍ពិពាហ៍រួមមានដូចជា៖

**៣.២.២.១ ភាគីជាសហព័ទ្ធផ្ទាល់**

ភាគីដែលរៀបអាពាហ៍ពិពាហ៍ មានសិទ្ធិឲ្យលុបចោលនូវអាពាហ៍ពិពាហ៍នៅពេលដែលបានដឹងអំពីភាពមិនប្រក្រតីចំពោះអាពាហ៍ពិពាហ៍របស់ខ្លួនដែលមានលក្ខខណ្ឌចាំបាច់ ក្នុងការហាមឃាត់ដូចជា អាយុមិនគ្រប់

[38] មាត្រា ៩៥០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ក្នុងការរៀបអាពាហ៍ពិពាហ៍។ ចំណងអាពាហ៍ពិពាហ៍ជាមួយញាតិលោហិត ឬញាតិពន្ធ មិនឲ្យមានទ្វេពន្ធភាព អំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មី។

ក្នុងករណីនេះមានតែភាគីដែលរៀបអាពាហ៍ពិពាហ៍ដោយផ្ទាល់ទេ ទើបមានសិទ្ធិដាក់ពាក្យបណ្ដឹងលុបចោលនោះបាន។ បុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍ដោយការឆបោក ឬការគំរាមអាចធ្វើការទាមទារទៅតុលាការឲ្យលុបចោលអាពាហ៍ពិពាហ៍បាន។ ដើម្បីការពារជនដែលបានរៀបអាពាហ៍ពិពាហ៍ដោយការឆបោក ឬការគំរាមកំហែង សិទ្ធិលុបចោលអាពាហ៍ពិពាហ៍ ត្រូវបានផ្ដល់ឲ្យចំពោះភាគីនៃអាពាហ៍ពិពាហ៍តែប៉ុណ្ណោះ ដែលត្រូវបានប្រគល់សិទ្ធិឲ្យ។ ភាគីម្ខាងនៃការលុបចោល គឺជាភាគីម្ខាងទៀតនៃអាពាហ៍ពិពាហ៍ ដោយរាប់បញ្ចូលទាំងករណីឆបោក ឬ គំរាម ដែលត្រូវបានធ្វើឡើងដោយតតិយជនផងដែរ។

**៣.២.២.២ ញាតិរបស់ភាគី**

សាច់ញាតិរបស់ភាគីនីមួយៗ ក៏អាចដាក់ពាក្យបណ្ដឹងលុបចោលអាពាហ៍ពិពាហ៍បានដូចគ្នា។ កាលណាបើបានដឹងថា អាពាហ៍ពិពាហ៍នោះផ្ទុយនឹងបញ្ញត្តិមាត្រា៩៦០ នៃក្រមរដ្ឋប្បវេណី។ ក្នុងខ្លឹមសារច្បាប់បានអនុញ្ញាតឲ្យញាតិរបស់ភាគីនៃចំណងអាពាហ៍ពិពាហ៍មានសិទ្ធិក្នុងការប្ដឹងលុបចោលអាពាហ៍ពិពាហ៍ វាពិតជាមានសារៈសំខាន់ខ្លាំងណាស់ ពីព្រោះអាចការពារអំពីស្ថានភាពនៃភាគីចំណងអាពាហ៍ពិពាហ៍នោះមិនហ៊ានធ្វើការប្ដឹងអំពីការលុបចោលនោះទេ ដោយសារកត្តាណាមួយដែលអាចជាការគ្មានឱកាស ការគំរាមគំហែងណាមួយ ឬដោយសារឥទ្ធិពលនៃអំណាចគ្រួសារ ឬឥទ្ធិពលហិរញ្ញវត្ថុជាដើម។

**៣.២.២.៣ តំណាងអយ្យការ**

ព្រះរាជអាជ្ញា អាចចូលរួមក្នុងនីតិវិធីនៃបណ្ដឹងបានតែក្នុងនីតិវិធីបណ្ដឹងដែលទាក់ទងនឹងឋានៈបុគ្គលទេ។ តំណាងអយ្យការ អាចដាក់ពាក្យបណ្ដឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍បាន។[39] ប្រសិនបើយល់ឃើញថា វាមានភាពចាំបាច់ត្រូវការពារដល់ផលប្រយោជន៍សាធារណៈ។[40] ពិសេសអំពីបុគ្គលដែលមានសិទ្ធិទាមទារឲ្យលុបចោល ម្យ៉ាងវិញទៀតត្រូវកំណត់ផងដែរថា អំពីការទាមទារត្រូវធ្វើឡើងដោយការដាក់ពាក្យទៅតុលាការដោយសារអនុភាព នៃការលុបចោលនៃអាពាហ៍ពិពាហ៍ចាំបាច់ត្រូវធ្វើការកំណត់ជាស្ថាពរហើយមានលក្ខខណ្ឌជាឯកសណ្ឋាន។ ក្នុងករណីដែលភាគីជាអនីតិជនអ្នកដែលមានតួនាទីការពារភាគីនោះមិនមែនជាព្រះរាជអាជ្ញាទេ គឺជាអ្នកតំណាងដែលច្បាប់បានកំណត់ មានដូចជាអ្នកដែលមានអំណាចមេបា ឬ អ្នកអាណាព្យាបាលទូទៅជាដើម។ តំណាងអយ្យការដែលជាអ្នកតំណាងឲ្យផលប្រយោជន៍ជាសាធារណៈសិទ្ធិទាមទារឲ្យលុបចោលរបស់តំណាងអយ្យការនោះ នឹងត្រូវរលត់ប្រសិនបើសហព័ទ្ធម្ខាងទៀតទទួលមរណៈភាព។

[39] មាត្រា ៩៦០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[40] មាត្រា ៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

## ៣.៣ អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍

ការលុបចោលអាពាហ៍ពិពាហ៍មិនមានអានុភាពប្រតិសកម្មទេ។[41] នេះវាបានសេចក្ដីថាការលុបចោលអាពាហ៍ពិពាហ៍មិនមានអានុភាពទៅលើអតីតកាលនោះទេ តែវាមានអានុភាពរំលាយអាពាហ៍ពិពាហ៍ឆ្ពោះទៅរកថ្ងៃអនាគតនៃចំណងរៀបអាពាហ៍ពិពាហ៍នោះ។ ក្រោយពេលដែលតុលាការបានប្រកាសសាលក្រមលើសេចក្ដីសម្រេចក្នុងការលុបចោលអាពាហ៍ពិពាហ៍នោះចូលជាស្ថាពរ។

ជាការពិតណាស់ នៅពេលមានបណ្ដឹងកើតឡើងភាគីទាំងសងខាងរមែង នឹងទទួលរងនៅការខូចខាតចំពោះបណ្ដឹងទាមទារឲ្យការលុបចោលអាពាហ៍ពិពាហ៍ក៏មិនខុសគ្នាដែរ។ ចំពោះភាគីដែលមិនបានដឹងអំពីមូលហេតុនៃការលុបចោលនៅពេលរៀបអាពាហ៍ពិពាហ៍ ក្នុងករណីប្រសិនបើទទួលបានទ្រព្យសម្បត្តិដោយការរៀបអាពាហ៍ពិពាហ៍នោះ ត្រូវសងទ្រព្យសម្បត្តិនោះត្រឹមកម្រិតដែលផលប្រយោជន៍ទទួលបាន។[42]
ចំពោះទ្រព្យសម្បត្តិដែលទទួលបានដោយការរៀបអាពាហ៍ពិពាហ៍រួមមាន៖

- ទ្រព្យសម្បត្តិដែលត្រូវធ្វើជាប្រទានកម្ម នៅពេល នឹងក្នុងពេលរៀបអាពាហ៍ពិពាហ៍
- ទ្រព្យសម្បត្តិដែលទទួលបានតាមរយៈសន្តតិកម្ម នឹងអច្ច័យទានជាដើម។

### ៣.៣.២ អានុភាពចំពោះបុគ្គល

អានុភាពដែលត្រូវបានកើតមានឡើងនោះគឺ ចំពោះបុគ្គល ហើយបុគ្គលនៅទីនេះត្រូវបានធ្វើការបែងចែកជាពីរគឺ៖ សាមីខ្លួនទាំងសងខាង និងចំពោះបុត្តភាព។

#### ៣.៣ ១.២.ចំពោះសាមីខ្លួនទាំងសងខាង

នៅពេលអានុភាពនៃសាលក្រមលុបចោលអាពាហ៍ពិពាហ៍ នឹងអាចឲ្យជីវិតគូរត្រូវមានការប្រែប្រួលទៅតាមគ្នាដែរ ហើយផ្លាស់ប្ដូរទៅជាមានលក្ខណៈជីវិតបែបនៅលីវទៅវិញ។ ដោយសារអាពាហ៍ពិពាហ៍ដែលមានអានុភាពដែលអ្នកទាំងពីរបានបង្កើតឡើងនោះក៏ត្រូវក្លាយជាឥតបានការ។ ទន្ទឹមនេះផងដែរ ចំណងគតិយុត្តមួយចំនួនក៏ត្រូវបានរលាយមានករណីជាច្រើនដែលត្រូវកើតឡើងចំពោះពួកគេ ករណីកិច្ចដែលប្ដីប្រពន្ធរួមរស់ជីវភាពជាមួយគ្នា ការសហការគ្នា ការសង្គ្រោះគ្នាទៅវិញទៅមក។[43] ជាពិសេសនាមត្រកូលដែលសហពទ្ធ័ម្ខាងបានផ្លាស់ប្ដូរ ទៅជាបានត្រកូលរបស់សហពទ្ធ័ម្ខាងទៀត។[44] ក៏ប៉ុន្តែនៅមានបញ្ហាមួយចំនួនជាបន្តបន្ទាប់ពីក្រោយ

[41] កថាខណ្ឌទី១ នៃមាត្រា ៩៦៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[42] កថាខណ្ឌទី២ នៃមាត្រា ៩៦៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[43] មាត្រា ៩៦៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[44] មាត្រា ៩៦៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ទៀតនៃការរំលាយអាពាហ៍ពិពាហ៍របស់ពួកគេផងដែរនោះគឺបញ្ហា៖ កូន និងការបែងចែកទ្រព្យសម្បត្តិវាកាន់តែជារឿងដែលមានភាពស្មុគស្មាញ និងមានការយកចិត្តទុកដាក់បំផុត។

**៣.៣.២.២ ចំពោះបុត្តភាព**

ពេលដែលមានការលុបចោលអាពាហ៍ពិពាហ៍ ពិតណាស់ឥទ្ធិពលដែលជះខ្លាំងជាងគេ គឺទៅដល់កូន ដោយហេតុថាឪពុកម្តាយត្រូវបានបែកបាក់ហើយក្លាយជាអ្នកដទៃ។ ដូច្នេះហើយឪពុកម្តាយដែលត្រូវបានបែកបាក់ ត្រូវកំណត់យកភាគីណាម្ខាង ជាអ្នកមានអំណាចមេបាតាមការពិភាក្សា ឬ ការព្រមព្រៀង របស់ភាគីទាំងសងខាង។ ប៉ុន្តែប្រសិនបើការពិភាក្សាមិនបានសម្រេច ឬពុំមានការពិភាក្សាទេ តុលាការត្រូវកំណត់អ្នកមានអំណាចមេបា ដោយពិចារណាទៅលើផលប្រយោជន៍របស់កូននោះ។[45] ករណី បើអាពាហ៍ពិពាហ៍ត្រូវបានលុបចោល មុនពេលកំណើតរបស់កូនម្តាយ គឺជាអ្នកមានអំណាចមេបាបាន។

❖ ចំពោះទារកដែលទើបនឹងកើតត្រូវបានគេសន្មតបិតុភាពរបស់កូនដូចខាងក្រោម
  - ទារកនៅក្នុងផ្ទៃម្តាយដែលមាននៅក្នុងចំណងអាពាហ៍ពាហ៍ ត្រូវសន្មតថាជាកូនរបស់ប្តីនោះ
  - កូនដែលបានកើតឡើងនៅក្នុងអំឡុងពេល ១៨០ (មួយរយប៉ែតសិប) ថ្ងៃគិតចាប់ពីថ្ងៃរៀបអាពាហ៍ពិពាហ៍ ឬក្នុងអំឡុងពេល ៣០០ (បីរយ) ថ្ងៃ គិតចាប់ពីថ្ងៃដែលបានរំលាយ ឬលុបចោលអាពាហ៍ពិពាហ៍នោះសន្មតថាជាកូនរបស់បុរសដែលជាប្តីនៃម្តាយ។[46]
  - ក្នុងករណីដែលស្ត្រី បានរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ផ្ទុយនឹងបញ្ញត្តិនៃមាត្រា៩៥០ ក្នុងអំឡុងពេលហាមឃាត់ មិនអោយរៀបអាពាហ៍ពិពាហ៍ថ្មីទៀតនៃក្រមនេះ បានបង្កើតកូន ប្រសិនបើមិនអាចកំណត់ឪពុករបស់កូននោះ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ និងទី២ខាងលើនេះទេ ត្រូវសន្មតថា កូននោះជាកូនរបស់ប្តីដែលបានរៀបអាពាហ៍ពិពាហ៍ក្រោយ។

ការកំណត់អ្នកមានអំណាចមេបា ឬ ការចាត់ចែងពាក់ព័ន្ធនឹងការចិញ្ចឹមបីបាច់ថែរក្សាកូន។ តុលាការត្រូវសួរនាំ នឹងត្រូវគិតពិចារណានូវយោបល់ក្នុងការសម្រេចសេចក្តីដែលមើលទៅតាមអាយុ ឬ មើលទៅតាមភាពនៃការយល់ដឹងរបស់កូន ពិសេសតុលាការសម្រេចសេចក្តីដោយផ្អែកទៅលើផលប្រយោជន៍នៃកូននោះ។

---

[45] មាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[46] មាត្រា ៩៦៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ៣.៣.៣ អនុភាពចំពោះទ្រព្យ

ជាការពិតណាស់ ក្រោយពីបានលុបចោលអាពាហ៍ពិពាហ៍ បញ្ហាដែលប្រឈមគ្រប់បែបយ៉ាង វានឹងត្រូវបានកើតមានឡើង។ ការលុបចោលអាពាហ៍ពិពាហ៍កើតឡើងចម្បងមួយទៀតនោះ គឺទ្រព្យសម្បត្តិ វាជាបញ្ហាមួយដែលកើតក្រោយបន្ទាប់ពីសំណងនៃការខូចខាតបានដោះស្រាយរួចរាល់។

#### ៣.៣.៣.១ ចំពោះទ្រព្យសកម្ម

ត្រង់នេះមិនថាមុនពេល ឬក្រោយរៀបអាពាហ៍ពិពាហ៍លុបចោលទេ ច្បាប់ខ្មែរត្រូវបានផ្តល់សិទ្ធិសេរីភាពឲ្យសហពទ្ធ័ទាំងសងខាងជ្រើសរើសប្រពន្ធ័គ្រប់គ្រងទ្រព្យសម្បត្តិប្តី-ប្រពន្ធដែលខ្លួនពេញចិត្ត។ ហេតុនេះហើយនៅពេលដែលមានការបែកបាក់គ្នាការបែងចែកទ្រព្យសម្បត្តិនឹងត្រូវបានបែងចែកទៅតាមលក្ខខណ្ឌ ឬបញ្ញាត្តិដែលបានកំណត់ក្នុងប្រពន្ធ័នីមួយៗដែលប្រពន្ធ័គ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធនោះចែកចេញជាពីរគឺៈ ប្រពន្ធ័ទ្រព្យសម្បត្តិតាមកិច្ចសន្យា នឹងប្រពន្ធ័ទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់។

#### ក. ប្រពន្ធ័ទ្រព្យសម្បត្តិតាមវិធានកិច្ចសន្យា

វិធាននៃកិច្ចសន្យាត្រូវបានធ្វើឡើងដើម្បីទប់ស្កាត់វិវាទទ្រព្យសម្បត្តិនោះ ដើម្បីបញ្ជាក់ឲ្យច្បាស់លាស់អំពីទំនាក់ទំនងនៃសិទ្ធិ និងករណីកិច្ចរបស់ប្តីប្រពន្ធ ពោលគឺសហពទ្ធ័ទាំងសងខាងត្រូវបានផ្តល់លទ្ធភាព ដែលអាចកំណត់ដោយខ្លួនឯងនូវសមាសភាពនៃទ្រព្យរួម វិធាននៃការគ្រប់គ្រង ព្រមទាំងការជម្រះបញ្ជី និងការបែងចែករបបមាតិកភណ្ឌគ្រួសារ។ ប៉ុន្តែបញ្ញត្តិនេះមិនអាចធ្វើផ្ទុយទៅនឹងបញ្ញាត្តិស្តីពីសិទ្ធិទាមទារ អាហារកាតព្វកិច្ច នឹងភាគបម្រុងបានឡើយ។[47] កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយត្រូវចុះបញ្ជីឲ្យបានត្រឹមត្រូវនៅក្រសួងយុត្តិធម៌ ដើម្បីអាចយកទៅតតាំងជាមួយនឹងតតិយជនបាន។[48] ម៉្យាងទៀតការជ្រើសរើសយកប្រពន្ធ័ទ្រព្យសម្បត្តិតាមកិច្ចសន្យា វាមានភាពងាយស្រួលដល់ស្ថាប័នតុលាការ ព្រមទាំងជៀសវាងនូវវិវាទវែងឆ្ងាយរវាងគូរភាគី ដែលបែងចែកទ្រព្យសម្បត្តិក្រោយពេលអាពាហ៍ពិពាហ៍ ត្រូវបានរំលាយដោយភាគីគ្រាន់តែអនុវត្តតាមបញ្ញត្តិដែលបានកំណត់ក្នុងកិច្ចសន្យានោះជាការស្រេច។

#### ខ. ប្រពន្ធ័ទ្រព្យសម្បត្តិកំណត់តាមច្បាប់

ក្រោយពីរៀបអាពាហ៍ពិពាហ៍រួច ប្រសិនបើសហព័ទ្ធទាំងសងខាងមិនបានបង្ហាញឆន្ទៈថាត្រូវជ្រើសរើសយកប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិណាមួយនោះទេ។ គេអាចសន្មតថាពួកគេរើសយកប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ដោយស្វ័យប្រវត្តិ។ នៅក្នុងប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់នេះ គេធ្វើការបែងចែកទ្រព្យសម្បត្តិប្តីប្រពន្ធជាពីរប្រភេទគឺៈទ្រព្យសម្បត្តិរួម នឹងទ្រព្យសម្បត្តិដោយឡែក។

[47] កថាខណ្ឌទី២ នៃមាត្រា ៩៦៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[48] កថាខណ្ឌទី១ នៃមាត្រា ៩៧០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

❖ **ទ្រព្យសម្បត្តិរួមៈ**

ទ្រព្យសម្បត្តិរួម ជាទ្រព្យសម្បត្តិទាំងឡាយដែលប្ដីឬប្រពន្ធទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ តែលើកលែងតែទ្រព្យសម្បត្តិ ដែលកំណត់ថាជាទ្រព្យសម្បត្តិដោយឡែក។[49] សហព័ទ្ធទាំងសងខាងមានសិទ្ធិស្មើគ្នាចំពោះការចាត់ចែងទ្រព្យសម្បត្តិរួម នៅក្នុងការប្រើប្រាស់ដើម្បីទទួលបានផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរួមនោះ។ ប៉ុន្តែការប្រើប្រាស់ទ្រព្យសម្បត្តិរួមនោះ ត្រូវស្ថិតក្នុងទំហំដែលចាំបាច់។ ហើយផ្អែកទៅលើការទំនុកបម្រុងក្នុងការទ្រទ្រង់ជីវភាព។[50] ការចាត់ចែងទ្រព្យសម្បត្តិរួមយកទៅលក់ ឬធ្វើការចាត់ចែងផ្សេងទៀត ដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត ឬទាំងសងខាងមិនត្រូវបានអនុញ្ញាតឡើយ[51]។ ករណីនេះគឺការពារនៅពេលមានការបែកបាក់នៅថ្ងៃណាមួយរវាងភាគីទាំងសងខាង។ ដូច្នេះទ្រព្យរួមត្រូវធ្វើការបែងចែកដោយយុត្តិធម៌ ដោយផ្អែកលើការពិភាក្សានឹងការព្រមព្រៀងទាំងសងខាងមុននឹងធ្វើការចាត់ចែង ។ បើមានវិវាទកើតឡើង ចំពោះការប្រើប្រាស់ នឹងមិនមានការសុខបចិត្តចំពោះការសម្រេចនេះ ភាគីអាចលើកពីស្ថានភាពផ្សេងទៅកាន់តុលាការដើម្បីផ្ញើការពិចារណាលើទំហំលើការបរិច្ចាកលទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ។ ព្រមទាំងផលប្រយោជន៍ទាក់ទងនឹងកូនជាដើម ចំពោះអាហារកិច្ចត្រូវចាត់ទុកថាមានតម្លៃស្មើនឹងការងារដែលនៅក្រៅផ្ទះដែរ។

❖ **ទ្រព្យសម្បត្តិដោយឡែកៈ**

ទ្រព្យសម្បត្តិដោយឡែក ជាទ្រព្យសម្បត្តិដែលសហព័ទ្ធម្ខាងមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ ទ្រព្យនេះជាទ្រព្យដែលទទួលបានពីប្រទានកម្ម សន្តតិកម្ម អច្ច័យទាន និង ទ្រព្យដែលជាតម្លៃតបដែលទទួលបានតាមរយៈការចាត់ចែងទ្រព្យសម្បត្តិដោយឡែកផ្សេងទៀត។[52]នៅក្រោយពេលជីវភាពអាពាហ៍ពិពាហ៍ត្រូវបានបន្តទៅមុខទៀតនោះ ឬ កាន់តែយូរទៅៗមានករណីជាច្រើនដែលទ្រព្យសម្បត្តិមានមុនពេលរៀបអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិដែលទទួលបានក្នុងអំឡុងពេលរៀបការបានបង្កឲ្យការបែងចែកច្បាស់លាស់ ថាជាទ្រព្យផ្ទាល់ខ្លួន ឬ ជាទ្រព្យរួមដែលបណ្ដាលឲ្យក្លាយទៅជាវិវាទ នៅពេលមានការបែងចែកទ្រព្យកើតឡើង។ ដើម្បីងាយស្រួលដល់ភាគីទាំងសងខាង នឹងជាដំណោះស្រាយផងនោះ ភាគីគប្បីធ្វើជាបញ្ជីទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធ ដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់រវាងទ្រព្យដោយឡែក និងទ្រព្យរួម។ ទ្រព្យសម្បត្តិដោយឡែកនេះ មិនមែនជាកម្មវត្ថុនៃការបែងចែកនៅពេលដែលភាគីមានការបែកបាក់គ្នានោះទេពីព្រោះទ្រព្យប្រភេទនេះគឺ វាស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហា

[49] មាត្រា ៩៧៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[50] មាត្រា ៩៧៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[51] មាត្រា ៩៧៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[52] មាត្រា ៩៧២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ព័ន្ធតែម្ខាងដែលជាម្ចាស់កម្មសិទ្ធិប៉ុណ្ណោះ។ ហេតុនេះហើយ ក្រោយពេលអាពាហ៍ពិពាហ៍ត្រូវបានលុបចោល ភាគីមិនអាចប្ដឹងទាមទារឲ្យធ្វើការបែងចែកទ្រព្យសម្បត្តិដោយឡែករបស់ភាគីម្ខាងទៀតបានឡើយ។

**៣.៣.៣.២ ចំពោះអកម្មទ្រព្យ**

អកម្មទ្រព្យ គឺជាបំណុលដែលត្រូវបានគេយកមកធ្វើការបែងចែកផងដែរ ក្រោយពេលមានការលុបចោលអាពាហ៍ពិពាហ៍។ អកម្មទ្រព្យនេះត្រូវបានបែងចែកជាពីរគឺៈ អកម្មទ្រព្យដោយឡែក និង អកម្មទ្រព្យរួម។

**ក. អកម្មទ្រព្យដោយឡែក**

អកម្មទ្រព្យដោយឡែក ឬ ហៅថាបំណុលផ្ទាល់ គឺជាបំណុលដែលសហព័ន្ធម្ខាងបានជាប់ជំពាក់នាមុនពេលរៀបអាពាហ៍ពិពាហ៍។ ក៏ប៉ុន្តែអាចនឹងមានករណីមួយចំនួនទៀត ដែលសហព័ទ្ធម្ខាងជាប់ជំពាក់ក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ ដែលបានឲ្យសហព័ទ្ធម្ខាងដឹងពីការជំពាក់នោះ។ ការខ្ចីយកទៅប្រើប្រាស់ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ឬ ជាការខ្ចីយកទៅប្រើប្រាស់ឥតប្រយោជន៍ ដូច្នេះបំណុលនេះក៏មិនមានការពាក់ព័ន្ធជាមួយសហព័ទ្ធម្ខាងឲ្យទទួលខុសត្រូវចំពោះបំណុលនោះឡើយ។

ដូចគ្នាផងដែរ បំណុលដែលអាចចាត់ទុកថាចាបំណុលផ្ទាល់ លុះត្រាតែភាគីម្ខាងទៀតមិនមានភស្តុតាងផ្ទុយ ហើយបើគ្មានការបង្ហាញភស្តុតាងទេ ទោះបីខ្ចីយកទៅធ្វើអ្វីក៏ដោយ ក៏ត្រូវចាត់ទុកថាជាបំណុលរួមដែរ ហេតុនេះភស្តុតាងសម្រាប់បញ្ជាក់យ៉ាងសំខាន់បំផុត។

**ខ. អកម្មទ្រព្យរួម**

អកម្មទ្រព្យរួម ឬ បំណុលរួម ជាបំណុលដែលកើតនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ វាជាកាតព្វកិច្ចរួមរបស់សហព័ទ្ធទាំងសងខាង ដែលបំណុលនោះកើតចេញពីការចំណាយ ដើម្បីរក្សាជីវភាពរួមរបស់ប្ដី ប្រពន្ធដែលការចំណាយទៅលើការអប់រំ ការព្យាបាល ការថែរក្សាកូន ព្រមទាំងការដោះដូរដើម្បីទំនុកបម្រុងជាប្រចាំ ឬ ជាកាតព្វកិច្ច នឹង ករណីកិច្ចផ្សេងៗទៀតដែលត្រូវបំពេញដែលសហព័ទ្ធណាម្ខាង ត្រូវទទួលបន្ទុកដោយមានការយល់ព្រមពីសហព័ន្ធម្ខាងទៀត។ ចំពោះការព្រមព្រៀងខាងលើនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរឲ្យបានត្រឹមត្រូវនឹងមានភាពច្បាស់លាស់។[53] ដើម្បីជៀសវាងការដាក់បន្ទុកធ្ងន់ធ្ងរទៅលើតែភាគីម្ខាងៗ ហើយភាគីម្ខាងទៀតនៃអកម្មទ្រព្យរួមនេះបែរជាយករួចតែខ្លួនជាដើម។

[53] មាត្រា ៩៧៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានឆ្លងកាត់នូវការសិក្សាស្រាវជ្រាវអំពីប្រធានបទដែលស្តីអំពី **មោភាព និងការលុបចោលអាពាហ៍ពិពាហ៍**រួចមក។ វាពិតជាបានឆ្លុះបញ្ចាំងយ៉ាងច្បាស់នូវរបៀបរបបប្រកាន់យកនូវទំនៀមទម្លាប់តរៀងមក ហើយក៏បានបង្ហាញអំពីបែបបទនៃច្បាប់យ៉ាងសម្បូរបែបក្នុងការដំណើរប្រព្រឹត្តទៅនៃអាពាហ៍ពិពាហ៍។ បើទោះបីជាមានប្រព័ន្ធច្បាប់ក្នុងការឃុំគ្រង ដើម្បីឲ្យអាពាហ៍ពិពាហ៍មួយមានលក្ខណៈល្អប្រសើរទៅតាមទម្រង់ច្បាប់ក៏ដោយ យើងឃើញថាវិការៈនៃអាពាហ៍ពិពាហ៍នេះនៅតែបន្តកើតមានក្នុងសង្គមជាតិសព្វថ្ងៃ។

តាមរយៈការសិក្សាស្រាវជ្រាវនូវ ប្រធានបទនេះរួចមកកត្តាដែលឈានទៅដល់ការមោឃ និងការលុបចោលអាពាហ៍ពិពាហ៍នេះវាបណ្តាលមកពីកត្តាជាច្រើនបានគួបផ្សំគ្នា អ្វីដែលជារឿងសំខាន់នោះគឺភាគីខ្លួនឯងផ្ទាល់ដែលជាសហព័ទ្ធ កត្តាមនោសចេតនារបស់ចាស់ទុំ និងការយល់ដឹងអំពីប្រព័ន្ធយុត្តាធិការនៅមានកម្រិតនៅឡើយ។ ក្នុងនោះមោឃភាពនៃអាពាហ៍ពិពាហ៍ត្រូវបានមើលឃើញមានមូលហេតុចម្បងចំនួនពីរចំណុចធំៗដែលរួមមានកត្តាគ្មានឆន្ទៈក្នុងការរៀបអាពាហ៍ពិពាហ៍ និងមិនគោរពទៅតាមនីតិវិធិនៃទម្រង់រដ្ឋបាល។ ចំណែកឯការលុបចោលនូវអាពាហ៍ពិពាហ៍វិញយើងឃើញមានមូលហេតុមួយចំនួនដែលរួមមានអាពាហ៍ពិពាហ៍ ប្រព្រឹត្តឡើងរវាងញាតិដែលច្បាប់បានហាមឃាត់ ភាគីម្ខាងនៃសហព័ទ្ធមិនគ្រប់អាយុ ដោយការឆបោកឬគំរាមគំហែងការហាមឃាត់មិនឲ្យមានទ្វេពន្ធភាពជាដើម។ ជាហេតុនាំឲ្យមានផលវិបាកទៅដល់ភាគីទាំងសងខាង ហើយមិនត្រឹមតែប៉ុណ្ណោះវាបានជះឥទ្ធិពលអាក្រក់ទៅដល់កូនៗជាទីស្រលាញ់ និងទ្រព្យសម្បត្តិទាំងឡាយដែលតែងតែលិតខំប្រឹងប្រែងស្វែងរកគ្រប់ការលំបាកក៏ត្រូវធ្វើការបែងចែងគ្នារៀងៗខ្លួន។ ជារួមទាំងការមោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍ វាសុទ្ធតែត្រូវបានធ្វើឡើងនៅតុលាការ ពីព្រោះអាពាហ៍ពិពាហ៍វាជាកិច្ចសន្យាដ៏ឱឡារឹកមួយរវាងបុរស-នារីដែលមិនអាចមានជនណាត្រូវបានធ្វើការរំលាយដោយងាយៗ និងធ្វើឡើងតាមតែទំនើងចិត្តរបស់ខ្លួនដោយឯកឯងបានទេ។ ទោះបីជាច្បាប់បានបញ្ញត្តិយ៉ាងនេះក្តីក៏ពិតមែនក៏ប៉ុន្តែក្នុងសង្គមយើងសព្វថ្ងៃនេះវិការៈទាំងអស់នេះនៅតែបានកើតមានឡើង នៅក្នុងប្រទេសយើងដដែលតែវាមិនមានច្រើនពេកដែលនាំឲ្យមានក្តីកង្វល់ខ្លាំងខ្លាពន់ពេកនោះទេ។ ទាំងអស់នេះវាបានបង្ហាញថាការផ្សព្វផ្សាយពីវិស័យច្បាប់នៅមានកម្រិតមិនទាន់ជូនល្មមនៅឡើយ ដែលវាមិនទាន់បានឆ្លើយតបទៅនឹង ស្ថានភាពជាក់ស្តែងរបស់សង្គមដែលមានការអភិវឌ្ឍតតឈប់ឈរនោះទេ យ៉ាងណាមិញទោះបី ជារាជរដ្ឋាភិបាល ឬភាគីដែលពាក់ព័ន្ធទាំងឡាយបានខិតខំធ្វើការអប់រំផ្សព្វផ្សាយយ៉ាងណាក៏ដោយ វានៅតែមិនអាចធ្វើឲ្យដំណើរការស់នៅប្រចាំថ្ងៃ ពិសេសទាក់ទងទៅនឹងចំណងអាពាហ៍ពិពាហ៍នោះត្រឹមត្រូវបានគ្រប់យ៉ាងដែរ នេះវាទាមទារឲ្យយើងជាពលរដ្ឋនៅក្នុងសង្គមចូលរួមទាំងអស់គ្នា។

ឆ្លងកាត់តាមការអធិប្បាយសេចក្តីនៃការមោឃភាព និងការលុបចោលនៃអាពាហ៍ពិពាហ៍ខាងលើនេះ យើងអាចសន្និដ្ឋានបានថាជាក់ស្តែងនៃសង្គមកម្ពុជាបច្ចុប្បន្ននៅតែកើតមានអំពីបញ្ហាខាងលើនេះ ដែលជាក្តីកង្វល់មួយរបស់សង្គមជាតិ។ ដូច្នេះវាទាមទារឲ្យមានការលើកកម្ពស់នូវការផ្សព្វផ្សាយប្រព័ន្ធច្បាប់ឲ្យបានកាន់តែប្រសើរឡើងបន្ថែមទៀតក្នុងការដោះស្រាយ ក៏ដូចជាកាត់បន្ថយមិនឲ្យមានបញ្ហាប្រឈមខាងលើនេះកើតមានឡើងក្នុងសង្គមជាតិបន្តទៀត។ ដើម្បីឲ្យមានការមោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍នេះធានាបាននូវតម្លាភាពដល់សង្គមគ្រួសារក្នុងប្រទេសជាតិ គឺទាមទារឲ្យពលរដ្ឋម្នាក់ៗមានម្ចាស់ការលើខ្លួនឯងក្នុងការយល់ដឹងពីច្បាប់ឲ្យបានច្រើនបន្ថែមទៀត។

# អនុសាសន៍

ដើម្បីជាការឆ្លើយតបទៅនឹងបញ្ហា នៃប្រធានបទដែលបានលើកឡើងមកខាងលើនេះ យើងខ្ញុំទាំងពីររូប សូមសំណូមពរទៅដល់ភាគីពាក់ព័ន្ធដូចជា៖

**១. រាជរដ្ឋាភិបាល៖** ជាពិសេសស្ថាប័នដែលមានការជាប់ពាក់ព័ន្ធនានាបន្តធ្វើការពង្រឹង ក្នុងការលើកកម្ពស់នូវផ្សព្វផ្សាយចំណេះដឹងផ្នែកទៅកាន់ប្រជាពលរដ្ឋឲ្យបានទូលំទូលាយបន្ថែមទៀត។ តាមរយៈនូវការដាក់បញ្ចូលក្នុងកម្មវិធីសិក្សាក្តី តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ឬធ្វើការផ្សព្វតាមរយៈច្បាប់ទៅកាន់ទីតាំងដល់សហគមន៍ផ្ទាល់ ជាពិសេសអ្នកដែលរស់នៅតំបន់ដាច់ស្រយាលពិតជាមិនសូវទទួលនូវពុទ្ធិផ្នែកច្បាប់នោះទេដោយមានកម្រិតទន់ខ្សោយនៅឡើយស្របពេលដែលច្បាប់ថ្មីៗត្រូវបានបង្កើតឡើងជាបន្តបន្ទាប់។

**២. ស្ថាប័នតុលាការ៖** សូមមេត្តាជួយពន្លឿននូវការដោះស្រាយរឿងក្តីដែលប្រជាពលរដ្ឋបានដាក់ បណ្តឹងទៅឲ្យបានឆាប់រហ័ស និងមានប្រសិទ្ធិភាពជាងនេះបន្ថែមទៀត ពីព្រោះកាលណានីតិវិធីនៃការដោះស្រាយមានភាពយឺតយ៉ាវធ្វើឲ្យប្រជាពលរដ្ឋមិនសប្បាយ ពិសេសការរងចាំនូវការដោះស្រាយទាំងត្រេកត្រអាល។

**៣. មន្ត្រីរាជការ សិស្ស និស្សិត៖** បុគ្គលទាំងនេះ ត្រូវបានសង្គមចាត់ទុកជាបញ្ញាវ័ន្ត ដែលជាអ្នកមានចំណេះដឹងទូលំទូលាយ។ ដូចនេះគួរណាតែអ្នកទាំងអស់នេះមានការចូលរួមចំណែកធ្វើការផ្សព្វផ្សាយនូវចំណេះដឹងទៅកាន់ប្រជាពលរដ្ឋនៅក្នុងសង្គមជាតិឲ្យបានតាមដែលអាចធ្វើទៅបាន នឹងត្រូវធ្វើជាគម្រូវល្អសម្រាប់ប្រជាពលរដ្ឋទូទៅឲ្យគេអនុវត្តតាម។

**៤. ប្រជាពលរដ្ឋ៖** ប្រជាពលរដ្ឋគួរតែចូលរួមក្នុងការគោរពច្បាប់ឲ្យបានខ្ជាប់ខ្ជួន ដើម្បីឲ្យសង្គមពោលពេញទៅដោយប្រជាពលរដ្ឋល្អ ដែលជាហេតុនាំឲ្យសង្គមមានរបៀបរៀបរយ និងមានការចូលរួមសិក្សាស្វែងយល់នូវច្បាប់ថ្មីៗដែលតែងតែកើតមានឡើងជាបន្តបន្ទាប់បន្ថែម។ ព្រោះពួកយើងទាំងអស់គ្នារស់នៅក្នុងសង្គមនីតិរដ្ឋត្រូវតែមានការយល់ដឹងអំពីច្បាប់ គឺជារឿងដែលសំខាន់នឹងមានភាពចាំបាច់ជាទីបំផុត។ ពិសេសសូមមេត្តាអាណាព្យាបាលគ្រប់រូបមិនគួរណាមានការបង្ខិតបង្ខំទៅលើកូនរបស់ខ្លួនក្នុងការរៀបអាពាហ៍ពិពាហ៍ឡើយ គឺត្រូវតែទុកនូវឱកាសទៅដល់ ពួកគេនៅក្នុងការជ្រើសរើសគូរស្រករបស់ពួកគេដែលមានការពេញចិត្ត នឹងគ្នាទៅវិញទៅមក។

# ឯកសារយោង

## I. រដ្ឋធម្មនុញ្ញ

១. រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

## II. ក្រម និងច្បាប់នានា

២. ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

៣. ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

៤. ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩

៥. ច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ២០០៦

៦. ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១

៧. ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០

៨. ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០

## III. អនុក្រឹត

៩. អនុក្រឹតស្តីពី មន្ត្រីអត្រានុកូលដ្ឋាន ឆ្នាំ២០០០

១០. អនុក្រឹត លេខ១៨៣ អនក្រ.បក ចុះថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

## IIII. សៀវភៅ និងឯកសារផ្សេងៗ

១១. សៀវភៅជំនួយស្មារតី នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ ដែលរៀបរៀងដោយ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១៧

១២. សៀវភៅ នីតិរដ្ឋប្បវេណី រៀបរៀងដោយ លោកសាស្ត្រាចារ្យ អម សុផាណារ៉ាត ឆ្នាំសិក្សា ២០១៦-២០១៧

១៣. សៀវភៅ នីតិរដ្ឋប្បវេណី១ របស់ក្រុមការងារសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ចាប់ផ្តើមពីឆ្នាំ ២០១២-២០១៧

១៤. គេហទំព័ររបស់ នីតិកោសល

១៥. សន្ទានុក្រម នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

# ឧបសម្ព័ន្ធ

# បញ្ជីរាយនាមឧបសម្ព័ន្ធ

| | |
|---|---|
| ១ | ទម្រង់ឯកសារទាក់ទងទៅនឹង លិខិតរៀបអាពាហ៍ពិពាហ៍ |
| ២ | មាត្រាមួយចំនួនដែលជាប់ពាក់ព័ន្ធនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ |
| ៣ | ច្បាប់ស្តីពីឯកពន្ធភាពឆ្នាំ១៩៨៩ |
| ៤ | អនុក្រឹតស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស |
| ៥ | សាលក្រម |